# ជំហានអនុវត្តតាមគោលការណ៍ណែនាំពីការប៉ាន់ប្រមាណ ភាពងាយរងគ្រោះ និងសមត្ថភាព (វីស៊ីអេ)

## សម្រាប់អ្នកស្ម័គ្រចិត្ត និងអ្នកធ្វើការនៅមូលដ្ឋាននៃចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហម







តំបន់អាស៊ីប៉ាស៊ីហ្វិក
ការិយាល័យប្រចាំតំបន់អាស៊ីអាគ្នេយ៍

សហព័ន្ធអន្តរជាតិ
នៃសមាគមកាកបាទក្រហម និងអឌ្ឍចន្ទក្រហម

# របៀបវារៈសាកលរបស់ សហព័ន្ធអន្តរជាតិ (២០០៦-២០១០)

ក្នុងរយៈពេល២ឆ្នាំទៅមុខនេះ ចំណុចផ្តោតជាសមូហភាពរបស់សហព័ន្ធ គឺទៅលើការសំរេចឱ្យបាន នូវគោលដៅ និងអាទិភាពខាងក្រោមនេះ :

## គោលដៅរបស់យើង

**គោលដៅទី ១ :** កាត់បន្ថយអត្រាស្លាប់ និងរបួស បង្កដោយគ្រោះមហន្តរាយ

**គោលដៅទី ២ :** កាត់បន្ថយអត្រាស្លាប់ និងឈឺ បង្កឡើងដោយជម្ងឺនានា និងគ្រោះបន្ទាន់ក្នុងសេវាសុខភាពសាធារណៈ

**គោលដៅទី ៣ :** បង្កើនសមត្ថភាពសហគមន៍មូលដ្ឋាន សង្គមស៊ីវិល និងចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហម ក្នុងការដោះស្រាយស្ថានភាពងាយរងគ្រោះ និងគ្រោះបន្ទាន់តាមសហគមន៍

**គោលដៅទី ៤ :** លើកកម្ពស់ការគោរពវប្បធម៌ និងពូជសាសន៍ចម្រុះ កាត់បន្ថយអំពើហឹង្សា អំពើរើសអើង និងការបែងចែកក្នុងសង្គម

## អាទិភាពរបស់យើង

លើកកម្ពស់សមត្ថភាពរបស់យើងនៅថ្នាក់មូលដ្ឋាន តំបន់ និងអន្តរជាតិដើម្បីឆ្លើយតបចំពោះគ្រោះមហន្តរាយនិងគ្រោះ បន្ទាន់នៃសុខភាពសាធារណៈ ។

ពង្រីកសកម្មភាពរបស់យើង ធ្វើការជាមួយសហគមន៍ងាយ រងគ្រោះ ក្នុងការលើកកម្ពស់សុខភាព ការបង្ការជំងឺ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ។

បង្កើនឱ្យបានខ្លាំងក្លា នូវកម្មវិធី និងការតស៊ូមតិរបស់យើង ចំពោះមេរោគអេដស៍ និងជម្ងឺអេដស៍។

លើកឡើងជាថ្មីម្តងទៀត ការតស៊ូមិតិរបស់យើងលើអាទិភាពបញ្ហាមនុស្សធម៌ ជាពិសេសការប្រយុទ្ធប្រឆាំងនឹងភាពមិនអត់ អោនការប្រកាន់គំនិតរើសអើង បែងចែក និងត្រូវលើកកម្ពស់ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ។

© សហព័ន្ធអន្តរជាតិនៃសមាគមកាកបាទក្រហម និងអឌ្ឍចន្ទក្រហម

ផ្នែកណាក៏ដោយនៃឯកសារនេះ អាចត្រូវដកស្រង់ ចម្លង បកប្រែជាភាសាដទៃទៀត ឬ សម្រួលឃ្លា ដើម្បីបំពេញតម្រូវការនៅក្នុងស្រុកដោយពុំចាំបាច់ការអនុញ្ញាតិពីសហព័ន្ធអន្តរជាតិនៃសមាគមកាកបាទក្រហម និងអឌ្ឍចន្ទក្រហមឡើយ ដោយសារប្រភពខ្លឹមសារត្រូវបានថែងយ៉ាងច្បាស់លាស់រួចទៅហើយ ។

ផែនទីបានប្រើប្រាស់ក្នុងឯកសារនេះមិនបង្ហាញពីទស្សនៈរបស់សហព័ន្ធអន្តរជាតិនៃសមាគមកាកបាទក្រហមនិងអឌ្ឍចន្ទក្រហម ឬសមាគមជាតិដែលមានការពាក់ព័ន្ធផ្នែកច្បាប់នៃព្រំសីមានៃប្រទេសនីមួយៗ ឬអាជ្ញាធររបស់ខ្លួនទេ ។

រូបភាពខាងក្រៅ : កាកបាទក្រហមទីម័រ និងកាកបាទក្រហមឡាវ

២០០៩

សហព័ន្ធអន្តរជាតិនៃសមាគមកាកបាទក្រហម និងអឌ្ឍចន្ទក្រហម

**ការិយាល័យប្រចាំភូមិភាគអាស៊ីអាគ្នេយ៍ប្រចាំភូមិភាគអាស៊ីអាគ្នេយ៍**

អាគារ Ocean Tower ជាន់ទី១, ៥ បន្ទប់លេខ ១៧០/១១-១២

សយសុខុមវិតទី១៦ ផ្លូវរត់ចាដាពិសែក ខ្លងតើយ ក្រុងបាងកក

១០១១០ ប្រទេសថៃ

*Email: hungha.nguyen@ifrc.org*

*Web site: www.ifrc.org*

## ជំហានអនុវត្តតាមគោលការណ៍ណែនាំ ស្តីពីការថ៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព (វីស៊ីអេ)

# សម្រាប់អ្នកស្ម័គ្រចិត្ត និងអ្នកធ្វើការនៅមូលដ្ឋាននៃចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហម

### វីស៊ីអេ គឺជាឧបករណ៍ដ៏ប្រសើរបំផុតមួយ សម្រាប់ធ្វើផែនការសហគមន៍

របទសម្ព័ន្ធ នៃគោលការណ៍ណែនាំស្តីការថ៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព (វីស៊ីអេ)

នឹងមានបង្ហាញដូចខាងក្រោម

**រៀបចំធ្វើវីស៊ីអេនៅមូលដ្ឋាន**

**ថ្ងៃទី ១**

- ប្រជុំរៀបចំជាមួយសមាជិកសហគមន៍ដើម្បីទាញចំណាប់អារម្មណ៍ អំពីវីស៊ីអេ
- អង្កេតផ្ចិតផ្ចង់ (ដោយក្រុមការងារ និងជាមួយមនុស្សសំខាន់ៗក្នុងសហគមន៍)
- ធ្វើការគូសផែនទី
- ប្រជុំជាមួយសមាជិកសហគមន៍អំពីប្រវត្តិសហគមន៍ ប្រតិទិនរដូវកាល និងការវិភាគក្រុមពាក់ព័ន្ធ

**ថ្ងៃទី ២**

- ប្រជុំជាមួយសហគមន៍ ដើម្បីចែករំលែកលទ្ធផលដែលបានធ្វើការវិភាគពីថ្ងៃទី១ និងបញ្ចូលទិន្នន័យបន្ថែម ប្រសិនបើមាន
- ផ្ទៀងផ្ទាត់ផែនទីដែលបានធ្វើជាមួយមនុស្សសំខាន់ៗ
- សំភាសន៍ក្រុមគោលដៅ៖ កុមារ ស្ត្រី កសិករ/អ្នកនេសាទ/ កម្មករ (ការវិភាគនឹងផ្តោតលើមុខសញ្ញាបង្កគ្រោះមហន្តរាយនិងភាពងាយរងគ្រោះ)
- រៀបចំព័ត៌មានជាប្រព័ន្ធ និងរៀបចំការងារ សម្រាប់ថ្ងៃទី ៣ (ដំណើរការប្រែក្លាយភាពងាយរងគ្រោះ ទៅជាសមត្ថភាព)

**ថ្ងៃទី ៣**

- ប្រជុំជាមួយសមាជិកសហគមន៍ ដើម្បីកំណត់សកម្មភាពសម្រាប់ប្រែក្លាយ ពីភាពងាយរងគ្រោះទៅសមត្ថភាព និងអនុវត្តដំណើរការសកម្មភាពជាក់លាក់ សម្រាប់ការការពារ ការកាត់បន្ថយ និងការត្រៀមបង្ការ
- រៀបចំព័ត៌មានជាប្រព័ន្ធ និងចែករំលែកព័ត៌មានមុនពេលចេញពីសហគមន៍ ។

**ផែនការសកម្មភាពសហគមន៍ ដើម្បីឆ្លើយតបបញ្ហា**

**ដែលរកឃើញក្នុងពេលធ្វើថ៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព**

## ១. ប្រវត្តិ

ការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព (វីស៊ីអេ) គឺជាធាតុដ៏សំខាន់មួយសម្រាប់ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយរបស់សហព័ន្ធអន្តរជាតិកាកបាទក្រហម និងអឌ្ឍចន្ទក្រហម (សហព័ន្ធអន្តរជាតិ)។ ក្រោមការជួយឧបត្ថម្ភរបស់អង្គការឌីហ្វីត (DFID) និងនាយកដ្ឋានជំនួយមនុស្សធម៌សហគមន៍អឺរ៉ុប វិធីសាស្ត្រនៃការធ្វើវីស៊ីអេ ត្រូវបានធ្វើការកែសម្រួលឡើងវិញនៅដើមឆ្នាំ២០០៧ ហើយសមាគមជាតិជាច្រើន បានទទួលការបណ្តុះបណ្តាលពីការប្រើប្រាស់វិធីសាស្ត្រនៃការធ្វើវីស៊ីអេនេះ។

នៅតំបន់អាស៊ីអាគ្នេយ៍នាពេលបច្ចុប្បន្ននេះ ការប្រើប្រាស់វីស៊ីអេ ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) និងឧបករណ៍ប៉ាន់ប្រមាណហានិភ័យផ្សេងៗ ដើម្បីកំណត់ និងតាមដានហានិភ័យដែលបណ្តាលមកពីគ្រោះមហន្តរាយ ត្រូវបានយកមកប្រើប្រាស់យ៉ាងទូលំទូលាយ ក្នុងចំណោមសមាគមជាតិជាច្រើន។ ជាឧទាហរណ៍ គឺបន្ទាប់ពីមានស៊ូណាមិនៅមហាសមុទ្រឥណ្ឌា កាកបាទក្រហមឥណ្ឌូនេស៊ី (ដែលគេស្គាល់ថាជា PMI) បានបោះជំហានមុនគេ ដើម្បីធ្វើសកម្មភាពនេះ ដោយការប្រើប្រាស់ ទាំងវីស៊ីអេ និង GIS ក្នុងការកំណត់នូវហានិភ័យ និងដំណោះស្រាយសំខាន់ផ្សេងៗទៀតនៅក្នុងមូលដ្ឋាន សម្រាប់ធ្វើការស្តារឡើងវិញ និងកម្មវិធីផ្សេងៗ ដែលសហគមន៍ អាចធ្វើទៅបាននៅក្នុងតំបន់ដែលទទួលរងផលប៉ះពាល់ នៃខេត្តអាជេ (Aceh) និងយ៉ូយ៉ាកាតា (Yogyakarta)។ ផែនទីជាច្រើនត្រូវបានគេគូសឡើង ដើម្បីបង្ហាញលទ្ធផលដែលបានមកពីការអង្កេត/ពិនិត្យទីកន្លែងជម្រក និងតំបន់សម្រាប់ការសាងសង់ផ្ទះ។ ផែនទីនេះក៏ត្រូវបានប្រើប្រាស់ ដោយកាកបាទក្រហមឥណ្ឌូនេស៊ី ដើម្បីជួយកំណត់នូវគោលដៅ និងជំនួយជាអាទិភាព ព្រមទាំងកំណត់នូវប្រភេទជំនួយផ្សេងៗ និងប្រើប្រាស់វា ដើម្បីគៀងគរកធនធានរបស់ចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហមជាដៃគូ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ វគ្គបណ្តុះបណ្តាលវីស៊ីអេសម្រាប់តំបន់អាស៊ីអាគ្នេយ៍ ដែលមានកាកបាទក្រហមឡាវជាម្ចាស់ផ្ទះ ហើយមានសិក្ខាកាមចំនួន២៥នាក់ មកពីសមាគមជាតិផ្សេងៗក្នុងតំបន់ បានចូលរួម ដើម្បីសិក្សានូវវិធីសាស្ត្រ និងវិធានដែលបានមកពីការកែសម្រួលឡើងវិញនូវការបោះពុម្ពផ្សាយឯកសារវីស៊ីអេ របស់សហព័ន្ធអន្តរជាតិ។ សិក្ខាកាមទាំងអស់ បានធ្វើការសំណូមពរឱ្យបង្កើត និងរៀបចំទៅតាមប្រភេទសម្ភារៈឧបទ្ទេសណែនាំ ស្តីពីការធ្វើវីស៊ីអេ ដើម្បីឱ្យមានជាវិធាននៅថ្នាក់តំបន់ជារួមមួយ នៅក្នុងពេលធ្វើវីស៊ីអេ។ គំនិតនេះគឺស្របទៅតាមឧបករណ៍វីស៊ីអេរបស់សហព័ន្ធអន្តរជាតិសម្រាប់បរិបទនៅតំបន់អាស៊ីអាគ្នេយ៍ ដើម្បីធ្វើការគាំទ្រដល់ដំណើរការប៉ាន់ប្រមាណរបស់សមាគមជាតិ តាមរយៈការបង្កើតនូវគោលការណ៍ណែនាំនៅថ្នាក់តំបន់នេះ។ ផ្អែកលើបទពិសោធន៍របស់កាកបាទក្រហម អឌ្ឍចន្ទក្រហម និងអង្គការជាដៃគូពីខាងក្រៅ ក្នុងគោលបំណងជួយណែនាំដល់សមាគមជាតិ ក្នុងការអនុវត្តវីស៊ីអេ និងស្របទៅតាមដំណើរការអនុវត្តវីស៊ីអេទៅតាមប្រទេសរបស់ខ្លួន។

បញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើន ដែលបានជួបប្រទះនៅពេលបង្កើត និងអនុវត្តគម្រោង ឬកម្មវិធី គឺលទ្ធផលវីស៊ីអេមិនត្រូវបានធ្វើសមាហរណកម្ម និងទទួលយកឱ្យបានល្អប្រសើរថា វាជាឧបករណ៍សម្រាប់រៀបចំផែនការអភិវឌ្ឍន៍សហគមន៍ដែលមាននិរន្តរភាពនោះទេ។ លើសពីនេះទៀត គឺកង្វះខាតនៃការចូលរួមពីសហគមន៍ នៅតែកើតមានឡើង ដែលធ្វើឱ្យមានការរាំងស្ទះ លើការចូលរួមរបស់សហគមន៍ទាំងចំណេះដឹង និងសម្ភារៈសម្រាប់ការអនុវត្តវីស៊ីអេ ។ មេរៀនជាបទពិសោធន៍សំខាន់ៗមួយចំនួនដែលបានមកពីការអនុវត្តវីស៊ីអេនាបណ្តាឆ្នាំកន្លងមក ហើយដែលបានរកឃើញនៅពេលនេះ គឺសម្រាប់ជាគំនិតបង្ហាញនៅមុនពេល ក្នុងពេល និងក្រោយពេលធ្វើវីស៊ីអេនៅក្នុងថ្នាក់តំបន់។

## មេរៀនដាបនពិសោធន៍ ដែលបានមកពីការអនុវត្តន៍

### ក. ការធ្វើសមាហរណកម្ម និង ការបញ្ជ្រាប :

១- សមាគមជាតិនីមួយៗ គួរតែបង្កើតគោលបំណងឱ្យបានច្បាស់លាស់ តាំងពីពេលចាប់ផ្តើមដំណើរការធ្វើវីស៊ីអេ ដើម្បីធានាថានៅគ្រប់លំដាប់ថ្នាក់ ជាពិសេសនៅថ្នាក់សហគមន៍ជាមួយអ្នកស្ម័គ្រចិត្តកាកបាទក្រហម ព្រមទាំងអ្នកភូមិជាមួយអាជ្ញាធរមូលដ្ឋាន បានដឹងពីផែនការធ្វើវីស៊ីអេនេះ ។

២- កាកបាទក្រហមឥណ្ឌូនេស៊ី បានបញ្ចូលវីស៊ីអេ ទៅក្នុងកម្មវិធីសមាហរណកម្មការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយតាមសហគមន៍ (ICBRR) សម្រាប់ជាឧបករណ៍ប៉ាន់ប្រមាណ ឬជាចំនុចចាប់ផ្តើមនៃការអនុវត្តគម្រោង ។ ការវិភាគហានិភ័យ និងផែនទីមុខសញ្ញាបង្កគ្រោះមហន្តរាយ ដែលជាសមាសភាពមួយរបស់វីស៊ីអេ អាចជួយកំណត់រកសហគមន៍ ដែលប្រឈមមុខទៅនឹងហានិភ័យ ហើយជាកន្លែងសម្រាប់អនុវត្តគម្រោងកាត់បន្ថយហានិភ័យដោយគ្រោះមហន្តរាយផងដែរ ។

៣- លទ្ធផលដែលបានមកពីវីស៊ីអេ គឺមិនគួរប្រើសម្រាប់តែការងារគ្រប់គ្រងគ្រោះមហន្តរាយប៉ុណ្ណោះទេ ប៉ុន្តែគួរតែធ្វើសមាហរណកម្មជាមួយផ្នែកសុខភាព និងការគាំពារ ព្រមទាំងការអភិវឌ្ឍន៍ស្ថាប័នផងដែរ ។

៤- លទ្ធផលវីស៊ីអេ ត្រូវបានធ្វើការចែករំលែកជាមួយក្រុមពាក់ព័ន្ធផ្សេងៗទៀត ទាំងខាងក្នុង និងខាងក្រៅរបស់ចលនាកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ជាពិសេសជាមួយរដ្ឋាភិបាល ដើម្បីធ្វើសមាហរណកម្ម និងសកម្មភាពផ្សេងៗឱ្យកាន់តែប្រសើរឡើង ដូចជានៅកាកបាទក្រហមកម្ពុជា ឥណ្ឌូនេស៊ី និងវៀតណាម គេបានរួមបញ្ចូលអាជ្ញាធរមូលដ្ឋានក្នុងការងារនេះផងដែរ ។

### ខ. ការតស៊ូមតិ

១- គេគួរតែធ្វើការតស៊ូមតិ ទៅដល់ថ្នាក់ដឹកនាំរបស់សមាគមជាតិ ដើម្បីទទួលបាននូវការឧបត្ថម្ភគាំទ្រជា គោលការណ៍ (Policy) ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ដល់ដំណើរការ និងការប្រព្រឹត្តទៅនៃវីស៊ីអេ ។

២- បង្កើនការតស៊ូមតិឱ្យបាននៅគ្រប់លំដាប់ថ្នាក់ផ្សេងៗ ដើម្បីអាចផ្សារភ្ជាប់លទ្ធផល វីស៊ីអេជាមួយផែនការអភិវឌ្ឍន៍ សង្គមសេដ្ឋកិច្ចរបស់សហគមន៍ទាំងមូល ។

### គ. ការរៀបចំចងក្រងគម្រោង និង កម្មវិធី

១- ជ្រើសរើសបុគ្គលដែលសាកសមបំផុតដើម្បីចូលរួមពាក់ព័ន្ធ ។ ជាឧទាហរណ៍ កាកបាទក្រហមឥណ្ឌូនេស៊ី ដែលក្រុមស្នូលនៃវីស៊ីអេ ត្រូវបានបង្កើតឡើង ដោយរួមបញ្ចូលក្រុមការងារ ដែលមានចំណេះដឹង និងជំនាញក្នុងការធ្វើវីស៊ីអេ ដើម្បីទៅបណ្តុះបណ្តាលដល់ក្រុមត្រៀមបង្ការ និងឆ្លើយតបគ្រោះមហន្តរាយ (SATGANA) នៅថ្នាក់អនុសាខា បន្ទាប់មកក្រុមនេះផ្តល់វគ្គបណ្តុះបណ្តាលបន្ត ទៅក្រុមការងារនៅថ្នាក់ភូមិ ដែលមានឈ្មោះថា ក្រុមធ្វើសកម្មភាពនៅសហគមន៍ (Community Based Action Plan “CBAT” ) អំពីការធ្វើការប៉ាន់ប្រមាណយ៉ាងដូចម្តេច ដោយប្រើប្រាស់ វីស៊ីអេជាឧបករណ៍ប៉ាន់ប្រមាណ ។

២- នាយកដ្ឋាន/ផ្នែកផ្សេងៗរបស់សមាគមជាតិ ដូចជានាយកដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ នាយកដ្ឋានសុខភាព និងការងារអភិវឌ្ឍន៍ស្ថាប័ន ត្រូវសម្របសម្រួលគ្នា ដោយគិតគូពិចារណាលែលកយ៉ាងណា ដើម្បីធ្វើសមាហរណកម្មវីស៊ីអេទៅគ្រប់គម្រោង និងកម្មវិធី របស់សមាគម ជាតិ ហើយដែលប្រសើរបំផុតនោះ គឺរាល់ការធ្វើវីស៊ីអេគឺធ្វើរួមគ្នាជាមួយនាយកដ្ឋាន/ផ្នែកផ្សេងៗទៀតរបស់សមាគមជាតិ ។

៣- ការធ្វើវីស៊ីអេភាគច្រើន គឺក្នុងរូបភាពបំរើឱ្យថ្នាក់គម្រោងតែប៉ុណ្ណោះ ។ ដើម្បីឱ្យទទួលបានផលរយៈពេលវែង នោះផែនការជាយុទ្ធសាស្ត្ររបស់សមាគមជាតិ គួរតែរួមបញ្ចូលនូវវីស៊ីអេ និងការអន្តរាគមន៍រយៈពេលវែង ដល់សហគមន៍ដែលប្រឈមមុខនឹងហានិភ័យខ្ពស់ ។

## ឃ. ការពង្រឹងសមត្ថភាព

១- ដើម្បីពង្រឹងអំណាចសហគមន៍ ការធ្វើវីស៊ីអេគួរតែប្រើប្រាស់ធនធានសហគមន៍ ការចូលរួម និង ការប្តេជ្ញាចិត្ត របស់ពួកគេផ្ទាល់ ឱ្យបានជាកម្រិតអតិបរមានៅក្នុងដំណើរការទាំងមូល ។ ដើម្បីធានាឱ្យមានភាពជាម្ចាស់កម្មសិទ្ធិដោយសហគមន៍ ត្រូវតែមានការចូលរួមយ៉ាងពិតប្រាកដពីសហគមន៍ តាំងពីចាប់ផ្តើមរៀបចំគម្រោង តាមរយៈការត្រួតពិនិត្យ ការរំលឹកឡើងវិញ និងការវាយតម្លៃ ។

២- វាពិតជាសំខាន់ដែលឱ្យសមាជិកសហគមន៍ចូលរួមពាក់ព័ន្ធ តាំងពីចាប់ផ្តើមដំណើរការ ដើម្បីបង្កើនសមត្ថភាព របស់ពួកគេក្នុងការអនុវត្តសកម្មភាពបន្តទៅមុខទៀត ដើម្បីកាត់បន្ថយហានិភ័យ និងភាពងាយរងគ្រោះដែលគេប្រឈម និងកសាងសុវត្ថិភាព និងធ្វើឱ្យសហគមន៍ របស់ពួកគេ មានភាពរឹងមាំអាចទប់ទល់ទៅនឹង គ្រោះមហន្តរាយ ដែលមានន័យថា **"ធ្វើការជាមួយពួកគេ មិនមែនធ្វើការឱ្យពួកគេទេ"** ។

## ២. វិធានរបស់ចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហម

សមាគមជាតិកាកបាទក្រហម អឌ្ឍចន្ទក្រហម នៅតំបន់អាស៊ីអាគ្នេយ៍ លើការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ការកសាងសុវត្ថិភាព និងភាពធន់របស់សហគមន៍ទៅនឹងគ្រោះមហន្តរាយ ដែលមានដូចតទៅ ៖

១-ពង្រឹងសមត្ថភាពសមាគមជាតិ ដើម្បីផ្តល់នូវសេវាកម្មល្អប្រសើរ ដល់សហគមន៍ងាយរងគ្រោះបំផុត ។

២-លើកកម្ពស់នូវការយល់ដឹងជាទូទៅ និងចំណេះដឹងដល់សហគមន៍ ពីអ្វីខ្លះដែលសហគមន៍ត្រូវធ្វើ មុនពេល ក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយ ។

៣-កំណត់រកនូវការយល់ឃើញខុសឆ្គងទាំងឡាយរបស់សហគមន៍ អំពីគ្រោះមហន្តរាយ ហើយផ្តល់នូវចំណេះដឹងពិតប្រាកដ ដែលអាចឱ្យសហគមន៍មានសមត្ថភាព ដើម្បីដោះស្រាយបញ្ហាគ្រោះមហន្តរាយឱ្យកាន់តែប្រសើរឡើង ។

៤- ពង្រឹងសមត្ថភាពសហគមន៍ ឱ្យគេអាចកំណត់ និងពិនិតតាមដានស្ថានភាពមុខសញ្ញាបង្កគ្រោះមហន្តរាយ និងហានិភ័យទាំងឡាយដែលអាចប៉ះពាល់ដល់សហគមន៍និងធនធានផ្សេងៗ ដែលមានសម្រាប់ប្រើ ដើម្បីឆ្លើយតបបញ្ហាទាំងនោះ ។

**ការចាត់អាទិភាពបញ្ហាដោយសមាជិកសហគមន៍ កាកបាទក្រហមឡាវ**



៥- លើកទឹកចិត្តសហគមន៍ ដើម្បីចូលរួមសកម្មភាពការងារ ផ្នែកកាត់បន្ថយ (Mitigation) ដែលជាប្រយោជន៍អាចការងារអាយុជីវិត និងលើកស្ទួយ ជីវភាពរស់នៅរបស់ពួកគេ ។

៦- គាំទ្រនូវបណ្តាញការងារ និង ភាពជាដៃគូដែលលើកកម្ពស់ និងតស៊ូមតិក្នុងការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (ការការពារ ត្រៀមបង្ការ និង កាត់បន្ថយ) ។

## តើអ្វីទៅជាវីស៊ីអេ?

វីស៊ីអេ គឺជាការអង្កេត ដែលប្រើប្រាស់ឧបករណ៍តាមបែបចូលរួមខុសៗគ្នា ដើម្បីស្វែងយល់ពីកម្រិតនៃការប្រឈមមុខរបស់មនុស្សទៅនឹងមុខសញ្ញាគ្រោះមហន្តរាយនៅមូលដ្ឋាន។ វាក៏ជាឧបករណ៍ដែលអាចជួយដល់ការកំណត់នូវអាទិភាពទាំងឡាយ ហើយនាំទៅរកការរៀបចំសកម្មភាពដែលរួមចំណែកដល់ការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ ព័ត៌មាន ដែលបានពីវីស៊ីអេ **ត្រូវតែ** ផ្សារភ្ជាប់ជាមួយគំរោង-កម្មវិធី និង សកម្មភាពផ្សេងៗ ដើម្បីឱ្យមានការចូលរួមទាំងអស់គ្នា ដោះស្រាយ បញ្ហាខុសៗគ្នា ដែលបានរកឃើញ ។

## តើអ្វីទៅដែលមិនមែនជាវីស៊ីអេ ?

ការធ្វើវីស៊ីអេគឺមានដែនកំណត់របស់វា។ វាអាចប្រែក្លាយដំណើរការទាំងមូលឱ្យទៅជាខុសឆ្គងបាន ប្រសិនបើយល់មិនច្បាស់ហើយ នៅពេលយកទៅធ្វើមិនច្បាស់ទៀត។ ពេលខ្លះ ក្នុងដំណាក់កាលបង្រៀនពីវិធីសាស្ត្រធ្វើវីស៊ីអេទាំងមូល គឺត្រូវបានប្រើ ឬបរិយាយខុស ដោយបុគ្គលិកកាកបាទក្រហម អឌ្ឍចន្ទក្រហម និងអ្នកស្ម័គ្រចិត្ត ដែលព្យាយាមផ្សារភ្ជាប់ដំណើរការនេះជាមួយដំណើរការកសាងសមត្ថភាពរបស់ស្ថាប័ន និងអង្គការផ្សេងៗ ។

## ៣. ដំណើរការធ្វើវីស៊ីអេ និងគោលការណ៍ណែនាំ

### គោលការណ៍ណែនាំទាំង ១២ជំហាន ដើម្បីឱ្យ ការធ្វើ វីស៊ីអេមានប្រសិទ្ធិភាព (ប្រែក្លាយពីការអង្កេតឱ្យទៅជាសកម្មភាព)

***កម្រិត ១ : ការឧបត្ថម្ភគាំទ្រពីសមាគមជាតិ***

១- ត្រូវយល់ថាហេតុអ្វីបានជាវីស៊ីអេ ត្រូវបានគេស្នើឡើង

២- ការពន្យល់ពីសារៈសំខាន់នៃវីស៊ីអេ ( ថ្នាក់ដឹកនាំសមាគមជាតិ សាខា និង ដៃគូ)

៣- បង្កើតរចនាសម្ព័ន្ធគ្រប់គ្រង សម្រាប់អនុវត្តវីស៊ីអេ

៤- បង្កើតនូវគោលបំណងនៃការធ្វើវីស៊ីអេ ( ដូចជា នៅឯណា? )

***កម្រិត ២ : ពីការប៉ាន់ប្រមាណទៅជាការធ្វើផែនការ***

៥- រៀបចំផែនការធ្វើវីស៊ីអេ ( ដូចជា អ្នកណាគេនឹងធ្វើអ្វីខ្លះ ធ្វើយ៉ាងដូចម្ដេច ហើយនៅពេលណា)

៦- ដំណាក់កាលរៀបចំ

៧- ប្រើប្រាស់ឧបករណ៍អង្កេតដើម្បីរកព័ត៌មានជាមួយសហគមន៍

៨- រៀបចំព័ត៌មានជាប្រព័ន្ធវិភាគ និង បកប្រែទិន្នន័យ

៩- ផ្ដល់ព័ត៌មានត្រលប់ទៅសហគមន៍វិញ និងធ្វើការសម្រេចចិត្តថាអ្វីជាអាទិភាព និង សកម្មភាព សម្រាប់ប្រែក្លាយភាពងាយរងគ្រោះទៅជាសមត្ថភាព

***កម្រិត ៣ : ពីការធ្វើផែនការ ទៅជាធ្វើសកម្មភាព***

១០- ប្រែក្លាយភាពងាយរងគ្រោះឱ្យទៅជាសមត្ថភាព តាមរយៈការអនុវត្តសកម្មភាពដែលបានលើក

១១- ផ្ដល់ជាអនុសាសន៍ និងសរសេររបាយការណ៍ សម្រាប់អាជ្ញាធរមូលដ្ឋាន ម្ចាស់អំណោយ និងដៃគូផ្សេងៗ

១២- ការអន្តរាគមន៍ ឬសកម្មភាពរបស់សហគមន៍ សម្រាប់កាត់បន្ថយហានិភ័យដែលបានរកឃើញនៅកន្លែងណាដែលអាចអនុវត្តបាន ។

## ផ្នែកទី ១ : ការឧបត្ថម្ភគាំទ្រពីសមាគមជាតិ

**ជំហានទី ១ : ជាដំបូង និងជាសំនួរដ៏សំខាន់បំផុតគឺត្រូវយល់ថាហេតុអ្វី បានជាការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថ ភាពត្រូវបានគេស្នើឡើង ហើយវាអាចជួយអ្វីបានខ្លះដើម្បីកាត់បន្ថយភាពងាយរងគ្រោះនៅក្នុងសហគមន៍ ?**

**មុនពេលវាយតំលៃភាពងាយរងគ្រោះ និងសមត្ថភាពត្រូវសួរខ្លួនឯងថា**

- តើសមាគមជាតិរបស់អ្នក មានឆន្ទៈចូលរួមពាក់ព័ន្ធក្នុងការធ្វើការងារបែបលក្ខណៈចូលរួមជាមួយសហគមន៍ពីរយៈពេលមធ្យមទៅរយៈពេលវែងដែរ ឬទេ?
- តើការប៉ាន់ប្រមាណភាពងាយរងគ្រោះនិងសមត្ថភាព គឺជាដំណើរការដ៏សមស្របបំផុតសម្រាប់អ្វីដែលអ្នកព្យាយាមចង់សម្រេចបាន ឬក៏អ្នកមានវិធីសាស្ត្រអ្វីផ្សេងទៀតដែលអ្នកគួរតែយកមកប្រើប្រាស់ដែរឬទេ?
- តើអ្នកមានធនធាន និងជំនាញ ដើម្បីអនុវត្តការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព និងធ្វើការពិនិត្យតាមដានតទៅមុខទៀតដែរ ឬទេ?
- តើសមាគមជាតិរបស់អ្នកមានឆន្ទៈក្នុងការផ្តល់ថវិកាក្នុងការបណ្តុះបណ្តាលបុគ្គលិក និងអ្នកស្ម័គ្រចិត្តនៅក្នុងសហគមន៍ដែរឬទេ?
- តើមាននាយកដ្ឋានណាខ្លះដែលបានត្រៀមរៀបចំដើម្បីឆ្លើយតបទៅនឹងតម្រូវការដែលអាចកើតឡើងដោយសហគមន៍ អាចនឹងលើកឡើងហើយដែលទាំងនោះមិនមែនជាផ្នែកមួយនៃការងារគ្រប់គ្រងគ្រោះមហន្តរាយ?

**ចំនុចគួរចងចាំ :** ការសម្រេចចិត្តធ្វើការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព

មិនអាចចាត់ទុកថាជារឿងងាយស្រួលនោះទេវាត្រូវការពេលវេលាការខិតខំប្រឹងប្រែងនិងការទទួលខុសត្រូវយ៉ាងប្រាកដ

ជាតិ និង សាខា រួមទាំង សហគមន៍ផងដែរ ។

**ជំហានទី ២ : ពន្យល់ពីវីស៊ីអេដល់ថ្នាក់ដឹកនាំសមាគមជាតិ សាខា អាជ្ញាធរមូលដ្ឋាន និងអង្គការជាដៃគូ ដើម្បីឱ្យមានការគាំទ្រ ដល់ដំណើរការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាពទាំងមូល ។**

**ជំហានទី ៣ : បង្កើតរចនាសម្ព័ន្ធគ្រប់គ្រង សម្រាប់អនុវត្តវីស៊ីអេ**

រចនាសម្ព័ន្ធគ្រប់គ្រងនៅគ្រប់ផ្នែកផ្សេងៗ ត្រូវតែបង្កើតឡើងដើម្បីឱ្យការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាពប្រកបដោយប្រសិទ្ធិភាពខ្ពស់(សូមពិនិត្យមើលរូបទី១) ។

### គន្លឹះមានប្រយោជន៍មួយចំនួន សម្រាប់ការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រង

នៅពេលបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងត្រូវធានាថាកិច្ចការដូចមានខាងក្រោម ត្រូវបានបំពេញរួចរាល់ :

- រៀបចំបង្កើតឱ្យមានលក្ខខ័ណ្ឌការងារដើម្បីរួមបញ្ចូលនូវតួនាទីនិងភារកិច្ច(ការបែងចែកការងារ) ដល់គ្រប់អ្នកដែលពាក់ព័ន្ធទោះពួកគេជាផ្នែកមួយនៃគណៈកម្មការគ្រប់គ្រង ឬក៏មិនមែនក៏ដោយ (ឧ. ប្រធាន អគ្គលេខាធិការ ។ល។ )
- ទទួលបាននូវការប្តេជ្ញាចិត្តយ៉ាងច្បាស់លាស់ពីគ្រប់អ្នកដែលពាក់ព័ន្ធ។
- គ្រោងនូវអ្វីដែលជាតម្រូវការដើម្បីឱ្យរចនាសម្ព័ន្ធមានដំណើរការ(ពេលវេលា ធនធានបណ្តាញទំនាក់ទំនង ។ល។)
- កំណត់នូវសក្តានុពលនៃបញ្ហាដែលអាចកើតឡើង និងដំណោះស្រាយសមស្របទៅនឹងបញ្ហានោះ (ឧ. ទំនាក់ទំនងរវាងកម្រិតផ្សេងៗគ្នា) ។

- ធ្វើការកំណត់ថា នៅពេលណាដែលរចនាសម្ព័ន្ធនេះនឹងត្រូវបញ្ចប់ទៅវិញ ។

**រូបភាពទី១: រចនាសម្ព័ន្ធគ្រប់គ្រងសំរាប់អនុវត្តការប៉ាន់ប្រមាណភាពងាយ រងគ្រោះ និងសមត្ថភាព**




**ជំហានទី ៤: បង្កើតនូវគោលបំណងនៃការធ្វើ វីស៊ីអេ**

ចំនុចមួយចំនួនខាងក្រោម ដែលគួរចងចាំពេលបង្កើតនូវគោលបំណង :

- គោលបំណងរួមទូទៅ គួរតែឆ្លើយតបទៅនឹងសំនួរថា ហេតុអ្វីបានជាអ្នកចង់ធ្វើវីស៊ីអេ ?
- គោលបំណងជាក់លាក់ គួរតែបង្ហាញពីភាពច្បាស់លាស់ អាចវាស់វែងបាន អាចសម្រេចបានពិតប្រាកដ និង មានពេលវេលាច្បាស់លាស់ (SMART) រួមទាំងយល់ច្បាស់ទាំងអស់គ្នា អំពីគោលបំណងនេះ ។
- ប្រើប្រាស់ដំណើរការតាមបែបចូលរួម ដើម្បីបង្កើតនូវគោលបំណង ។
- ធ្វើការសម្រេចដោយការយល់ស្របគ្នា និងការប្តេជ្ញាចិត្តខ្ពស់ ក្នុងចំណោមអ្នកពាក់ព័ន្ធ ដើម្បីជៀសវាងបញ្ហានាពេលអនាគត ។
- បញ្ជាក់ពីទំហំ និងដែនកំណត់របស់វីស៊ីអេ ដោយឆ្លើយនឹងសំនួរ ដូចជា តើវីស៊ីអេនឹងអនុវត្តនៅកន្លែងណា? តើមានសហគមន៍ចំនួនប៉ុន្មាន និងសាខាមួយណា ដែលនឹងចូលរួមពាក់ព័ន្ធ? តើធនធានមនុស្ស និង ហិរញ្ញវត្ថុអ្វីខ្លះដែលអាចយកមកប្រើប្រាស់បាន?
- តើអ្វីខ្លះទៅជាចរិកលក្ខណៈ និង ការប្រព្រឹត្តរបស់សហគមន៍នៅកន្លែងដែលយើងនឹងអនុវត្តវីស៊ីអេ

## *កម្រិត ២ : ពីការប៉ាន់ប្រមាណទៅជាផែនការ*

**ជំហានទី ៥ :រៀបចំផែនការសំរាប់ចុះធ្វើការប៉ាន់ប្រមាណភាពរងគ្រោះ និងសមត្ថភាព**

ឥឡូវនេះ សមាគមជាតិរបស់អ្នកបានសម្រេចចិត្តធ្វើការប៉ាន់ប្រមាណភាពរងគ្រោះ និងសមត្ថភាពអ្នកមានរចនាសម្ព័ន្ធនៅនឹងកន្លែង និងគោលបំណងចាំបាច់ត្រូវបង្កើត ហើយអ្នកគ្រប់គ្នារីករាយក្នុងការចាប់ផ្តើមការងារចុះអនុវត្តការប៉ាន់ប្រមាណនេះ ។ តើអ្វីជាជំហានបន្ទាប់ទៀត? (សូមមើលតារាងទី១)

## ជំហានទី ១ : ដំណាក់កាលរៀបចំ

នៅដំណាក់កាលដំបូងនេះរួមបញ្ចូលនូវ :

- ការកំណត់អំពីសាខា និងសហគមន៍ ចូលរួម
- ការជ្រើសរើស និងការបណ្តុះបណ្តាលដល់បុគ្គលិក និងអ្នកស្ម័គ្រចិត្ត ( ក្រុមអនុវត្តការងារ)
- ការកំណត់ និងការទទួលបានមកវិញនូវធនធានសំខាន់ៗ ដូចជាធនធានមនុស្ស ( អ្នកស្ម័គ្រចិត្តកាកបាទក្រហម) និងធនធានហិរញ្ញវត្ថុ ។
- ការកំណត់ និងការជ្រើសរើសឧបករណ៍អង្កេត ដើម្បីយកមកប្រើប្រាស់នៅក្នុងការធ្វើវីស៊ីអេ

### ការកំណត់ និងជ្រើសរើសសហគមន៍គោលដៅ

- ➢ តើសហគមន៍មួយណាដែលងាយរងគ្រោះជាងគេ?
- ➢ តើសហគមន៍ចំនួនប៉ុន្មានដែលគួរតែធ្វើការប៉ាន់ប្រមាណពីភាពរងគ្រោះ និងសមត្ថភាព?
- ➢ តើសាខាធ្លាប់មានបទពិសោធន៍ក្នុងការធ្វើការងារជាមួយសហគមន៍ដែរឬទេ? តើការប៉ាន់ប្រមាណភាពរងគ្រោះ និងសមត្ថភាព អាចផ្សាភ្ជាប់ជាមួយសកម្មភាពផ្សេងៗទៀតរបស់សមាគមជាតិបានដែរឬទេ?
- ➢ តើសហគមន៍មានចំណាប់អារម្មណ៍ដែរឬទេ? តើសហគមន៍មានការរៀបចំបានគ្រប់ជ្រុងជ្រោយហើយឬនៅ?
- ➢ តើមានអង្គការក្រៅរដ្ឋាភិបាលណាខ្លះដែលធ្វើការនៅក្នុងសហគមន៍? តើអ្នកអាចធ្វើការក្នុងភាពជាដៃគូជាមួយពួកគេបានដែរឬទេ?

***សូមចងចាំថាទាំងនេះគឺអាស្រ័យទៅលើសមាជិកសហគមន៍ ជាអ្នកសម្រេចចិត្តថា តើពួកគេនឹងចូលរួមពាក់ព័ន្ធនៅក្នុងដំណើរការនេះដែរឬទេ។ ប្រសិនបើពួកគេសម្រេចចិត្តថានឹងចូលរួម ដូចនេះពួកគេនឹងអាចជួយដល់ក្រុមការងារ លើការប្រមូលព័ត៌មាន ។ ពួកគេដឹងយ៉ាងច្បាស់ថា តើនរណាខ្លះដែលក្រុមការងារ គួរពិភាក្សាជាមួយ ពេលណាជាពេលវេលាល្អបំផុត ដើម្បីជួបប្រជុំជាមួយប្រជាជន និង ជួបនៅទីកន្លែងណា ។***

តារាងទី១: គំរូម៉ាទ្រិកសំរាប់ការប៉ាន់ប្រមាណភាពរងគ្រោះ និងសមត្ថភាព

| ដំណាក់កាល | សកម្មភាព | អ្នកទទួលខុសត្រូវ | ធនធានដែលត្រូវការ | មករា | កុម្ភៈ | មិនា | មេសា |
|---|---|---|---|---|---|---|---|
| ការរៀបចំ | ១- | | | | | | |
| | ២- | | | | | | |
| ការអនុវត្តន៍ | ១- | | | | | | |
| | ២- | | | | | | |
| ការវិភាគ | ១- | | | | | | |
| | ២- | | | | | | |
| ការធ្វើផែនការ និង សកម្មភាពគម្រោង | ១- | | | | | | |
| | ២- | | | | | | |

ការចូលរួមរបស់ស្ត្រីក្នុងដំណើរការធ្វើការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព គឺពិតជាមានសារៈសំខាន់ណាស់ - កាកបាទក្រហមឡាវ



ខាងក្រោមនេះគឺជាសំណើរលើកឡើងពីការ ធ្វើការប៉ាន់ប្រមាណភាពរងគ្រោះ និងសមត្ថភាព ពីមួយថ្ងៃទៅមួយថ្ងៃនៅមូលដ្ឋានជាមួយនឹងលទ្ធផល រំពឹងទុក ។

## ថ្ងៃទី ១

១_ ការប្រជុំដំបូងជាមួយសមាជិកសហគមន៍ ដើម្បីពន្យល់ ពី វីស៊ីអេ

២_ ការអង្កេតផ្ទាល់ ( ទាំងការអង្កេតដោយខ្លួនឯង និងបន្ទាប់មកជាមួយមនុស្សសំខាន់ៗនៅក្នុងសហគមន៍)

៣_ ការគូសផែនទី

៤_ ប្រជុំជាមួយសមាជិកសហគមន៍ : តារាងប្រវត្តិសហគមន៍ ប្រតិទិនរដូវកាល និងការវិភាគក្រុមពាក់ព័ន្ធ

៥_ ការវិភាគព័ត៌មានជាដំបូង និងការរៀបចំព័ត៌មានជាប្រព័ន្ធ

## ១. ការប្រជុំដំបូងជាមួយសមាជិកសហគមន៍

ឈានទៅរកការព្រមព្រៀងគ្នា ក្នុងចំណោមសមាជិកក្រុមអំពីគោលបំណង និងលទ្ធផលនៃការប្រជុំ។ កុំលើកឡើងនូវការរំពឹងទុកខ្ពស់ពេក ហើយធានាថា សហគមន៍យល់ពីដំណើរការប៉ាន់ប្រមាណតាមបែបចូលរួម ដែលវាអាចជួយពួកគេឱ្យរកឃើញនូវវិធីបន្ថែមទៀត ដើម្បីជួយខ្លួនពួកគេផ្ទាល់ ។

គោលបំណងនៃការប្រជុំ គឺឱ្យសមាជិកសហគមន៍ទាំងអស់បានចូលរួមពាក់ព័ន្ធនៅក្នុងដំណើរការធ្វើវីស៊ីអេ។ ធានាថា សមាជិកសហគមន៍យល់ពីដំណើរការ និងសេចក្តីត្រូវការដើម្បីឱ្យលទ្ធផលដែលបានមក គឺសម្រាប់សហគមន៍ពួកគេផ្ទាល់ ។

បង្កើតការព្រមព្រៀងក្នុងការធ្វើផែនការការងារជាមួយសហគមន៍ដើម្បីធានាថា ពួកគេដឹងទាំងអស់នូវអ្វី ដែលក្រុមការងារកំពុងធ្វើហើយធ្វើយ៉ាងដូចម្តេច។ ធានាថានឹងមានការចូលរួមពីគ្រប់សមាជិកសហគមន៍ ។

ចុងបញ្ចប់ សួរទៅសមាជិកសហគមន៍ឱ្យចែករំលែកនូវមតិយោបល់របស់គេ ជាមួយក្រុមវីស៊ីអេ អំពីមុខសញ្ញាបង្កគ្រោះមហន្តរាយ/ ឧបសគ្គ/តម្រូវការ/បញ្ហាចំបងៗ ដែលពួកគេតែងជួបប្រទះ ។

## ២. ការអង្កេតផ្ទាល់

***ចំណាំថា លទ្ធផលនៃសកម្មភាពនេះនឹងត្រូវបានផ្ទៀងផ្ទាត់ជាមួយសហគមន៍ម្តងទៀត ។ សូមប្រុងប្រយ័ត្នជានិច្ច ក្នុងការកត់ត្រា និងប្រមូលព័ត៌មាន ព្រោះវានឹងរួមចំណែកយ៉ាងសំខាន់ ដើម្បីឈានទៅដល់ការព្រមព្រៀងទាំងស្រុងជាមួយសហគមន៍ អំពីភាពត្រឹមត្រូវនៃព័ត៌មានដែលបានប្រមូល ។***

ក្រុមការងារគួរតែធ្វើការអង្កេតដោយមានលក្ខណៈជាប្រព័ន្ធនូវវត្ថុផ្សេងៗ មនុស្ស ព្រឹត្តិការណ៍ ការទំនាក់ទំនង ការចូលរួម និងកត់ត្រានូវរាល់អ្វីដែលឃើញពីការអង្កេតទាំងនោះ ។ វាផ្តល់ឱ្យយើងឃើញនូវទិដ្ឋភាពល្អប្រសើរមួយ អំពីស្ថានភាពគ្រោះមហន្តរាយ/មុខសញ្ញាបង្កគ្រោះមហន្តរាយ ជាពិសេសគឺ ព័ត៌មានដែលទាក់ទងនឹងអ្វីដែលពិបាកនឹងរៀបរាប់ប្រាប់ដោយផ្ទាល់មាត់ ។ នេះគឺជាវិធីសាស្ត្រមួយ សម្រាប់ធ្វើការចុះពិនិត្យឡើងវិញនូវព័ត៌មានផ្ទាល់មាត់ ។

### វិធីសាស្ត្រ ២ ក្នុងការអង្កេតផ្ទាល់ :

១- ការអង្កេតផ្ទាល់ និងការអង្កេតមិនផ្លូវការ

២- ការអង្កេតអ្នកចូលរួម

ខាងក្រោមនេះ គឺជាឧទាហរណ៍នៃការអង្កេតផ្ទាល់ដែលអាចជួយអ្នក ដើម្បីកំណត់នូវមុខសញ្ញាបង្កគ្រោះមហន្តរាយ និងសមត្ថភាព នៅមូលដ្ឋាន :

### ហេដ្ឋារចនាសម្ព័ន្ធ :

១- ប្រព័ន្ធប្រឡាយទឹក: តើមានឬទេ? ប្រភេទណា? ហើយនៅ ដំណើរការឬអត់?

២- អាគារ: រចនាបទស្ថាបត្យកម្មបែបណា? តើនៅជិត អាគារផ្សេងឬទេ? ប្រភេទសម្ភារៈ? ជម្រក?

៣- ប្រព័ន្ធបង្ហូរទឹក: តើមានឬទេ? ដំណើរការបានទេ? មានអាងស្តុកទឹកស្អុយ ប្រព័ន្ធបង្ហូរទឹកចេញ

៤- ការប្រើប្រាស់: អគ្គិសនី ទឹក ទូរស័ព្ទ

៥- សេវាកម្មសំខាន់ៗ : ដូចជា គ្លីនិកសុខភាព ប៉ុស្តិ៍ប៉ូលិស មន្ទីរពេទ្យ សាលារៀន ផ្សារ ការគ្រប់គ្រងកាកសំណល់រាវ ផ្លូវថ្នល់/ការដឹកជញ្ជូន ការិយាល័យប្រៃសណីយ៍ ។

### ការប្រតិបត្តិ និងភាពងាយរងគ្រោះ

១- សាលារៀន (អគ្គីភ័យ): គ្មានឧបករណ៍ពន្លត់អគ្គីភ័យ

២- ទីធ្លាកំសាន្ត (ការជ្រួលច្របល់): គ្មានរបងសុវត្ថិភាព និងមាន ច្រកចេញតែមួយ

៣- ស្ថានីយ៍ប្រេងឥន្ធនៈ (អគ្គីភ័យ): ជ្រាបហូរ និងគ្មានប្រព័ន្ធសុវត្ថិភាពការពារអគ្គីភ័យ

៤- ស្រះ (លង់ទឹក និង ជំងឺឆ្លង): ទឹកមិនហូរដែលនាំឱ្យមានក្លិនមិនល្អ

៥- ព្រះវិហារគ្រីស្តសាសនា/វិហារចាម/វត្ត : អាគារចាស់ទ្រុឌទ្រោម ការសាងសង់មិនត្រូវទៅតាមបច្ចេកទេស

### ស្ថានភាពសេដ្ឋកិច្ច-សង្គម

១- គ្រោងផ្ទះ : គ្រោងផ្ទះ ល្អ ឬ អន់

២- បរិស្ថាន : តើតំបន់នៅជុំវិញមានអនាម័យ និងមិនមានមុខសញ្ញាបង្កគ្រោះមហន្តរាយដែរឬទេ?

ចុងបញ្ចប់ សួរទៅសមាជិកសហគមន៍ឱ្យចែករំលែកនូវមតិយោបល់របស់គេ ជាមួយក្រុមវីស៊ីអេ អំពីមុខសញ្ញាបង្កគ្រោះមហន្តរាយ/ ឧបសគ្គ/តម្រូវការ/បញ្ហាចំបងៗ ដែលពួកគេតែងជួបប្រទះ ។

## ២. ការអង្កេតផ្ទាល់

***ចំណាំថា លទ្ធផលនៃសកម្មភាពនេះនឹងត្រូវបានផ្ទៀងផ្ទាត់ជាមួយសហគមន៍ម្តងទៀត ។ សូមប្រុងប្រយ័ត្នជានិច្ច ក្នុងការកត់ត្រា និងប្រមូលព័ត៌មាន ព្រោះវានឹងរួមចំណែកយ៉ាងសំខាន់ ដើម្បីឈានទៅដល់ការព្រមព្រៀងទាំងស្រុងជាមួយសហគមន៍ អំពីភាពត្រឹមត្រូវនៃព័ត៌មានដែលបានប្រមូល ។***

ក្រុមការងារគួរតែធ្វើការអង្កេតដោយមានលក្ខណៈជាប្រព័ន្ធនូវវត្ថុផ្សេងៗ មនុស្ស ព្រឹត្តិការណ៍ ការទំនាក់ទំនង ការចូលរួម និងកត់ត្រានូវរាល់អ្វីដែលឃើញពីការអង្កេតទាំងនោះ ។ វាផ្តល់ឱ្យយើងឃើញនូវទិដ្ឋភាពល្អប្រសើរមួយ អំពីស្ថានភាពគ្រោះមហន្តរាយ/មុខសញ្ញាបង្កគ្រោះមហន្តរាយ ជាពិសេសគឺ ព័ត៌មានដែលទាក់ទងនឹងអ្វីដែលពិបាកនឹងរៀបរាប់ប្រាប់ដោយផ្ទាល់មាត់ ។ នេះគឺជាវិធីសាស្ត្រមួយ សម្រាប់ធ្វើការចុះពិនិត្យឡើងវិញនូវព័ត៌មានផ្ទាល់មាត់ ។

### វិធីសាស្ត្រ ២ ក្នុងការអង្កេតផ្ទាល់ :

១- ការអង្កេតផ្ទាល់ និងការអង្កេតមិនផ្លូវការ

២- ការអង្កេតអ្នកចូលរួម

ខាងក្រោមនេះ គឺជាឧទាហរណ៍នៃការអង្កេតផ្ទាល់ដែលអាចជួយអ្នក ដើម្បីកំណត់នូវមុខសញ្ញាបង្កគ្រោះមហន្តរាយ និងសមត្ថភាព នៅមូលដ្ឋាន :

### ហេដ្ឋារចនាសម្ព័ន្ធ :

១- ប្រព័ន្ធប្រឡាយទឹក: តើមានឬទេ? ប្រភេទណា? ហើយនៅ ដំណើរការឬអត់?

២- អាគារ: រចនាបទស្ថាបត្យកម្មបែបណា? តើនៅជិត អាគារផ្សេងឬទេ? ប្រភេទសម្ភារ:? ជម្រក?

៣- ប្រព័ន្ធបង្ហូរទឹក: តើមានឬទេ? ដំណើរការបានទេ? មានអាងស្តុកទឹកស្អុយ ប្រព័ន្ធបង្ហូរទឹកចេញ

៤- ការប្រើប្រាស់: អគ្គិសនី ទឹក ទូរស័ព្ទ

៥- សេវាកម្មសំខាន់ៗ : ដូចជា គ្លីនិកសុខភាព ប៉ុស្តិ៍ប៉ូលិស មន្ទីរពេទ្យ សាលារៀន ផ្សារ ការគ្រប់គ្រងកាកសំណល់រាវ ផ្លូវថ្នល់/ការដឹកជញ្ជូន ការិយាល័យប្រៃសណីយ៍ ។

### ការប្រតិបត្តិ និងភាពងាយរងគ្រោះ

១- សាលារៀន (អគ្គីភ័យ): គ្មានឧបករណ៍ពន្លត់អគ្គីភ័យ

២- ទីធ្លាកំសាន្ត (ការជ្រួលច្របល់): គ្មានរបងសុវត្ថិភាព និងមាន ច្រកចេញតែមួយ

៣- ស្ថានីយ៍ប្រេងឥន្ធនៈ (អគ្គីភ័យ): ជ្រាបហូរ និងគ្មានប្រព័ន្ធសុវត្ថិភាពការពារអគ្គីភ័យ

៤- ស្រះ (លង់ទឹក និង ជំងឺឆ្លង): ទឹកមិនហូរដែលនាំឱ្យមានក្លិនមិនល្អ

៥- ព្រះវិហារគ្រីស្តសាសនា/វិហារចាម/វត្ត : អាគារចាស់ទ្រុឌទ្រោម ការសាងសង់មិនត្រូវទៅតាមបច្ចេកទេស

### ស្ថានភាពសេដ្ឋកិច្ច-សង្គម

១- គ្រោងផ្ទះ : គ្រោងផ្ទះ ល្អ ឬ អន់

២- បរិស្ថាន : តើតំបន់នៅជុំវិញមានអនាម័យ និងមិនមានមុខសញ្ញាបង្កគ្រោះមហន្តរាយដែរឬទេ?

៣-រចនាសម្ព័ន្ធគ្រួសារៈជាគ្រួសារដែលមានតែឪពុកម្តាយនិងកូនឬគ្រួសារធំដែលមានមនុស្សរស់នៅច្រើនតើក្មេងៗជាអ្នកមើលថែរក្សាក្មេងៗដូចគ្នាឬយ៉ាងណា ។

៤-ស្ថានភាពរស់នៅ ៖ តើមើលពីរូបភាពខាងក្រៅរបស់កុមារយ៉ាងណា (ទទួលបានអាហាររូបត្ថម្ភគ្រប់គ្រាន់កង្វះអាហាររូបត្ថម្ភ និងទីកន្លែងរស់នៅចង្អៀតខ្លាំងឬទេ?) តើកុមារគ្រប់អាយុចូលរៀនទៅរៀន ឬនៅផ្ទះ? តើមានមនុស្សពេញវ័យនៅថែរក្សាក្មេងៗនៅផ្ទះដែរឬទេ?

**ការប្រកបរបរចិញ្ចឹមជីវិត**

១- តើអ្វីជាប្រភពចំណូលសំខាន់បំផុតនៅក្នុងគ្រួសារៈ ឧ. សាច់ប្រាក់ដែលបានមកពីចម្ការ ដូចជា ស្រូវ ចម្ការ ស្វាយ ឬក៏ប្រភេទដាច់ដោយឡែកដែលបានមកពីការជួលទៅធ្វើការ ។

២- ចងចាំថា ឧបសគ្គផ្នែកទ្រព្យសម្បត្តិ ឬធនធានគឺវាមានសភាពខុសគ្នាពីកន្លែងមួយទៅកន្លែងមួយ ពីក្រុមមួយទៅក្រុមមួយ និង ទៅតាមប្រភេទនៃកម្រិតប្រាក់ចំណូល ។ ជាធម្មតា ក្រុមអ្នកក្រីក្រមានការពិបាកក្នុងការរកធនធាន និងមិនសូវមានមធ្យោបាយច្រើនសម្រាប់ប្រកបរបរចិញ្ចឹមជីវិត ជាងក្រុមអ្នក ដែលមានជាង ។

៣-ជាធម្មតា ក្រុមមនុស្សតាមប្រភេទផ្សេងៗគ្នា នៅក្នុងសហគមន៍មួយ មានបទពិសោធន៍ពីហានិភ័យខុសៗគ្នានៅក្នុងការប្រកបរបរចិញ្ចឹមជីវិត ។ ដូច្នេះប្រសិនបើយើងចង់កាត់បន្ថយភាពងាយរងគ្រោះ យើងត្រូវចាំបាច់ស្វែងយល់ឱ្យកាន់តែច្បាស់លាស់ពីកត្តាទាំងនេះ ។

ការចូលរួមរបស់ក្រុមជនជាតិភាគតិច គួរតែលើកយកមកពិចារណានៅកន្លែងណាដែលអាចអនុវត្តបាន-កាកបាទក្រហមវៀតណាម



**បែបផែននៃការរស់នៅ**

១- ទម្លាប់រស់នៅនិងសកម្មភាពប្រចាំថ្ងៃ

២- រចនាសម្ព័នគ្រួសារ

៣- ការជួយគ្នាទៅវិញទៅមក នៅក្នុងសហគមន៍

៤- សមត្ថភាព

៥- ជំនាញ

៦- អាគារប្រើប្រាស់ជាជម្រក/កន្លែងប្រជុំ

៧- ក្រុម អ្នកដឹកនាំចាត់ចែង

## ៣. ការគូរផែនទីសហគមន៍

មធ្យោបាយសំខាន់មួយក្នុងការប្រមូលទិន្នន័យវីស៊ីអេ គឺតាមរយៈការគូសផែនទីសហគមន៍ ។ ផែនទីនេះ វាផ្តល់ឱកាសឱ្យយើងកំណត់កាន់តែលំអិតថែមទៀត ពីភាពងាយរងគ្រោះ និង សមត្ថភាព ដូចជាលក្ខខ័ណ្ឌនៃការរស់នៅ ឥរិយាបទ និងកត្តាបរិស្ថាន ។

នាពេលបច្ចុប្បន្ននេះ ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) អាចផ្តល់ព័ត៌មានលំអិតបានជាច្រើន ដូចជាតំបន់មានហានិភ័យ និងភាពងាយរងគ្រោះសំខាន់ៗ ដោយមុខសញ្ញាបង្កគ្រោះមហន្តរាយជាក់

លាក់ណាមួយ ។ ប្រភេទព័ត៌មានទាំងនេះ គឺមានសារៈសំខាន់សម្រាប់ស្ថាប័នណាដែលធ្វើការងាលើការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ។

ទោះបីជាយ៉ាងណាក៏ដោយ ការគូសផែនទីសហគមន៍ជួយឱ្យសមាជិកសហគមន៍បានយល់ និងដឹងកាន់តែប្រសើរថែមទៀតអំពីស្ថានភាពផ្ទាល់របស់ពួកគេ ។ ព័ត៌មានតាមបែបបច្ចេកវិទ្យាប្រហែលជាមិនអាចឆ្លុះបញ្ចាំងអំពីស្ថានភាពនេះទេ ពីព្រោះស្ថានភាពហានិភ័យគឺវាពាក់ព័ន្ធនឹងការប្រព្រឹត្ត អាកប្បកិរិយាលក្ខខ័ណ្ឌរស់នៅ និងអត្តសញ្ញាណរបស់សហគមន៍ ។ ឧទាហរណ៍ ផែនទីសហគមន៍អាចឆ្លុះបញ្ចាំងពីស្ថានភាពប្រព័ន្ធប្រឡាយ និង ភាពដែលអាចខូចខាតទៅបាននៃប្រឡាយនេះដោយសារ តែការកើនឡើងនៃសម្រាម ។

ក្រុមការងារនឹងត្រូវធ្វើទៅតាមប្រភេទផែនទីដែលមានដូចតទៅនេះ :

**ផែនទី ទី១ :** ផែនទីគោល : បង្ហាញពីលក្ខណៈសំខាន់ៗទូទៅនៅក្នុងតំបន់ និងព្រំប្រទល់

**ផែនទី ទី២ :** ផែនទីមុខសញ្ញាបង្កគ្រោះមហន្តរាយ/ហានិភ័យ/ភាពងាយរងគ្រោះ : ធ្វើការកំណត់នូវមុខសញ្ញា និងហានិភ័យដែលកើតមាននៅក្នុងសហគមន៍ ។មុខសញ្ញានិមួយៗ គួរដាក់ផែនទីដាច់ដោយឡែកពីគ្នា ។

**ផែនទី ទី៣ :** ផែនទីសមត្ថភាព/ធនធាន : គូសផែនទី ដែលបង្ហាញពីធនធាន និងសមត្ថភាព ដែលមាននៅក្នុងសហគមន៍ ក៏ដូចជាភាពខុសគ្នានៃយ៉េនឌ័រជនជាតិភាគតិច និងតំបន់ប្រើប្រាស់ដីធ្លី ។

នៅពេលដែលផែនទីទាំងអស់ត្រូវបានគូសហើយក្រុមការងារត្រូវតែធ្វើការវិភាគនូវព័ត៌មាន និងកំណត់នូវអ្នកងាយរង គ្រោះបំផុត ។ បន្ទាប់មកផែនទីពំនូសកាត់ទទឹងភូមិ អាច នឹងត្រូវបានគូសឡើង (មើលផែនទីលំអិតទី៤ នៅខាងក្រោម) ។

## ការវិភាគទិន្នន័យ

កិច្ចការនេះគួតែធ្វើជាក្រុមទើបជាការប្រសើរបំផុត ។ ឧទាហរណ៍ទាំងឡាយខាងក្រោមនេះបង្ហាញពីហានិភ័យ និង សមត្ថភាព ដែលរកឃើញតាមរយៈការវិភាគផែនទី ដូចតទៅនេះ :

**ហានិភ័យ :**

- ការសាងសង់មានគុណភាពអន់ហើយផ្ទះដែលរស់ នៅជិតៗគ្នាទាំងនោះប្រឈមមុខនឹងហានិភ័យខ្ពស់នៃគ្រោះទឹកជំនន់
- ប្រជាជនមានចំណាកស្រុកដោយសារមានមនុស្សច្រើនហើយអត្រាអត់ការងារធ្វើខ្ពស់
- ប្រព័ន្ធទឹកស្អាតមិនត្រឹមត្រូវ បណ្តាលឱ្យមានជម្ងឺសើរស្បែកគ្រុនផ្តាសាយ ដូចជាចេញរោគសញ្ញាជម្ងឺផ្សេងៗ ។ល។
- ខ្វះការរៀបចំទុកដាក់សម្រាមដែលបណ្តាលឱ្យមានកើតពពួកសត្វករកេរ និងសត្វបំផ្លាញ
- ផ្ទះដែលរស់នៅជិតគ្នាប្រឈមមុខខ្ពស់ទៅនឹងអគ្គីភ័យ
- តំបន់ទាំងមូលនៅស្មើនឹងនីវ៉ូទឹកសមុទ្រដែលងាយនឹងមានមានទឹកជំនន់ ។

**សមត្ថភាព :**

- កម្រិតការអប់រំ ៣ ប្រភេទ ត្រូវបានរកឃើញនៅក្នុងតំបន់តែមួយ (បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ)
- ប្រជាជនមានឆន្ទៈក្នុងការចែករំលែកចំណេះដឹង និង ជំនាញ (ការនេសាទ ស្រែចម្ការ និង ជាងម៉ាស៊ីន...)
- មណ្ឌលសុខភាព មានផ្តល់សេវាកម្មថែទាំសុខភាព

- ឥឡូវនេះ ការគ្រប់គ្រងអនាម័យ អាចឆ្លើយតបទៅនឹងបញ្ហាសុខភាព
- ប្រជាជនមានឆន្ទៈក្នុងការពិភាក្សាលើបញ្ហាដែលកើតឡើងក្នុងសហគមន៍

**ផែនទី ទី ៤ :     ផែនទីពំនូសកាត់ទទឹងភូមិ**

នៅពេលគូសផែនទីពំនូសកាត់ទទឹងភូមិត្រូវពិចារណានូវចំនុច មួយចំនួនដូចខាងក្រោម :

- ការវិភាគព័តិមានពីផែនទីផ្សេងៗ ( ផែនទីគោល ផែនទីមុខសញ្ញាបង្កគ្រោះមហន្តរាយ/ហានិភ័យ/ភាពងាយរងគ្រោះ និងផែនទីធនធាន/សមត្ថភាព) ។
- គេត្រូវកត់សំគាល់ថា ជាផ្នែកមួយនៃការវិភាគពតិមាន ប្រសិនបើគេរកឃើញតំបន់ណាដែលប្រឈមមុខខ្លាំងនឹងមុខសញ្ញាបង្ករគ្រោះមហន្តរាយ ឬ ហានិភ័យ  នោះតំបន់នេះតម្រូវឱ្យមានការស្វែងយល់បន្ថែមពីភាពងាយរងគ្រោះឱ្យបានច្បាស់លាស់ផងដែរ ។
- ប្រជាជនមានចំណាកស្រុក  ដោយសារមានមនុស្សច្រើន ហើយអត្រាអត់ការងារធ្វើខ្ពស់
- គេធ្វើការវិភាគពីហានិភ័យគឺសំដៅលើការរកមើលថា តើនឹងមានសក្ដានុពលនៃមុខសញ្ញា ដែលគំរាមកំហែង សហគមន៍ដែរឬទេ។

ធាតុផ្សំអប្បបិរិមាដូចខាងក្រោម ដែលគួរតែរួមបញ្ចូល :

- ប្រភេទដី/សណ្ឋានដី
- តំបន់ជាក់លាក់ដែលជាកន្លែងប្រកបរបរចិញ្ចឹមជីវិតនៅក្នុងសហគមន៍
- កម្រិតនៃការរៀបចំចាត់ចែងនៅមូលដ្ឋាន
- មុខសញ្ញាបង្កគ្រោះមហន្តរាយ និង ហានិភ័យចំបងៗ
- លក្ខខ័ណ្ឌដែលធ្វើឱ្យភាពងាយរងគ្រោះកើនឡើង
- ជំនឿ និងគុណតម្លៃ
- សមត្ថភាព



ការវិភាគហានិភ័យ តាមរយៈផែនទី – កាកបាទក្រហមថៃ

**តារាងទី ២ : ឧទាហរណ៍ប្រវត្តិសហគមន៍តាមបែបរូបភាព**

| | មនុស្ស | ផ្ទះ | ដើមឈើ | សត្វពាហនៈ | សុខភាព | សម្ភារៈ |
|---|---|---|---|---|---|---|
| 1980 |  |  |  |  | ជំងឺរបេង/គ្រុនចាញ់ គ្រុនឈាម/ទឹកនោមផ្អែម/មហារីក |  |
| 1990 |  |  |  |  | ជំងឺរបេង/គ្រុនចាញ់ គ្រុនឈាម/ទឹកនោមផ្អែម/មហារីក /ជំងឺអេដស៍ |  |
| 2000 |  |  |  |  | ជំងឺរបេង/គ្រុនចាញ់ គ្រុនឈាម/ទឹកនោមផ្អែម/មហារីក /ជំងឺអេដស៍ |  |
| 2008 |  |  |  |  | ?????????? |  |

## ៤. ការប្រជុំជាមួយសមាជិកសហគមន៍

ការប្រជុំជាមួយសហគមន៍មានគោលបំណងពីរសំខាន់ៗ គឺ

**ក.** ប្រមូលព័ត៌មានឱ្យបានច្រើន ដោយប្រើប្រាស់ឧបករណ៍ ដូចមានបង្ហាញនៅក្នុងបញ្ជីខាងក្រោម

**ខ.** ផ្ទៀងផ្ទាត់ព័ត៌មានដែលបានមកពីការអង្កេតផ្ទាល់ដែលធ្វើដោយក្រុមជាមួយនឹងការបញ្ចូលព័ត៌មានផ្សេងៗទៀតពីមនុស្សសំខាន់ៗនៅក្នុងសហគមន៍

សូមចងចាំថា ដំណើរការតាមបែបចូលរួម គឺមានសារៈសំខាន់បំផុត ។ វាមិនមែនជាការបណ្តុះបណ្តាលទេ ។ វាត្រូវការប្រើប្រាស់នូវឧបករណ៍ និង វិធីសាស្ត្រ (សំនួរ-ចម្លើយ ការពិភាក្សាក្រុម ការសួរសំនួរបំផុសគំនិត ។ល។) អ្នកនឹងត្រូវធ្វើជាមួយសហគមន៍ នូវតារាងដូចតទៅនេះ :

- តារាងប្រវត្តិសហគមន៍ (Historical chart)
- ប្រវត្តិសហគមន៍ (Historical profile)
- ប្រតិទិនរដូវកាល
- ការវិភាគក្រុមពាក់ព័ន្ធ

នៅពេលដែលអ្នកធ្វើតារាងចប់ហើយ ត្រូវចែករំលែកលទ្ធផលពីការអង្កេតផ្ទាល់ជាមួយសហគមន៍ ដើម្បីទទួលបានព័ត៌មានត្រលប់ ការបញ្ចូលនូវព័ត៌មានថ្មី និងភាពជាម្ចាស់កម្មសិទ្ធិរបស់សហគមន៍។

### ប្រវត្តិសហគមន៍

នៅក្នុងសកម្មភាពនេះ ក្រុមការងារនឹងធ្វើការបង្ហាញនូវតារាងចំនួនពីរ គឺ :

- **តារាងទី ១** : ប្រវត្តិសហគមន៍តាមបែបរូបភាព (ដែលអាចមើលឃើញ)
- **តារាងទី ២** : ប្រវត្តិសហគមន៍ - តាមបែបបរិយាយ

ក្រុមការងារត្រូវប្រមូលព័ត៌មានអំពីអ្វីដែលបានកើតឡើងនៅក្នុងអតីតកាល ហើយផលិតជាកម្រងឯកសារសហគមន៍ និងប្រវត្តិសហគមន៍តាមបែបរូបភាព (ដែលអាចមើលឃើញ) ។ តំបន់ដែលជាផ្នែកមួយនៃការវិភាគ គួរតែធ្វើឱ្យបានកាន់តែទូលំទូលាយកាន់តែប្រសើរ ។ ការវិភាគទាំងនេះ រួមបញ្ចូលទាំងជម្ងឺ ការមានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ ការងារ គ្រោះមហន្តរាយចំបងៗ អំពើហិង្សា បទឧក្រិដ្ឋ ដើមឈើ និងជីវិតរស់នៅ ក្នុងចំណោមអ្វីៗផ្សេងទៀត ។ វាធ្វើឱ្យយល់កាន់តែច្បាស់ ពីមុខសញ្ញាដែលបានកើតឡើងកន្លងមក ការផ្លាស់ប្តូរទម្លាប់ និងការប្រព្រឹត្តរបស់សហគមន៍ ។ វាជួយឱ្យយើងយល់ពីស្ថានភាព នាពេលបច្ចុប្បន្ននៅក្នុងសហគមន៍ (កំណត់ទំនាក់ទំនងរវាងមុខសញ្ញាបង្កគ្រោះមហន្តរាយ និងភាពងាយរងគ្រោះ) នឹងធ្វើឱ្យយើងបានដឹងពីការប្រែប្រួលនាពេលកន្លងមក ។ (សូមមើលតារាងទី២)

តារាងដែលបានបង្កើតឡើងក្រុមការងារ (ទាំងក្រុមវីស៊ីអេ និងសហគមន៍) គួរតែឆ្លុះបញ្ចាំងពីប្រវត្តិសហគមន៍ ។ គួរលើកទឹកចិត្តក្រុមការងារឱ្យសួរសំនួរ ដូចជា :

- តើតារាងនេះ កំពុងប្រាប់អ្វីខ្លះដល់ខ្ញុំ?
- តើមានអ្វីខ្លះដែលបានកើតឡើង ?
- ហេតុអ្វីបានជាវាកើតឡើង ?
- តើមាននិន្នាការយ៉ាងដូចម្តេច?

ធ្វើការវិភាគតារាង ដោយប្រៀបធៀបបន្ទាត់ជួរឈរ និងជួរដេក ។ បន្ទាត់ជួរដេក គឺជាការអភិវឌ្ឍន៍និងព្រឹត្តិការណ៍ ដែលកើតឡើងមួយទសវត្សរ៍ហើយ ត្រូវបានប្រៀបធៀបជាមួយទសវត្សរ៍ដោយមើលពីលើ ឬពីក្រោម ។

## ប្រវត្តិសហគមន៍

កំឡុងពេលប្រមូលព័ត៌មាន ត្រូវរកមើលគ្រប់ទិដ្ឋភាព និងវិស័យទាំងឡាយក្នុងការងារអភិវឌ្ឍន៍សហគមន៍ ។ ចាប់ផ្តើមពីព័ត៌មានថាតើគេបានប្រើប្រាស់ដីនោះបានដោយរបៀបណា? ការសាងសង់ផ្ទះជាលើកដំបូងនៅលើដីទំនេរ ប្រភេទដំណាំ សត្វពាហនៈ ។ សូមចង្អុលបង្ហាញពីពេលវេលា និងអត្ថប្រយោជន៍ដែលបានបង្កើតឡើងយ៉ាងដូចម្តេចខ្លះ? សាលារៀនសង់នៅពេលណា? ហើយសហគមន៍អភិវឌ្ឍន៍សេដ្ឋកិច្ចយ៉ាងដូចម្តេច និងគ្រោះមហន្តរាយចំបងៗមានអ្វីខ្លះ ។ សូមមើលឧទាហរណ៍តារាងទី៣ខាងក្រោម ។

តារាងទី៣ : ឧទាហរណ៍ប្រវត្តិសហគមន៍

| ឆ្នាំ | បរិយាយ |
|---|---|
| 1970 | ការបង្កើតសហគមន៍ |
| 1972 | មានមនុស្សចំណាកស្រុក ចំនួន ៥០០០នាក់ បានមកដល់សហគមន៍ |
| 1973 | ជាដំបូង សង់សាលារៀន មណ្ឌលសុខភាព .... |
| 1980 | មានខ្យល់ព្យុះនីណា (Nina) |
| 1981 | កាកបាទក្រហមខេត្ត បានបង្កើតអ្នកស្ម័គ្រចិត្តចំនួន ៥នាក់ |
| 1983 | សង់វត្តអារាម |
| 1990 | មណ្ឌលសុខភាពត្រូវបានសង់រួចរាល់ |

## ប្រតិទិនរដូវកាល

ឧបករណ៍នេះ ត្រូវបានគេប្រើប្រាស់ ដើម្បីបង្ហាញពីព្រឹត្តិការណ៍ខុសៗគ្នា (ខ្យល់ព្យុះ ទឹកជំនន់) បទពិសោធន៍ (គ្រោះរាំងស្ងួតរយៈពេលវែង) សកម្មភាព (រដូវបុណ្យទាន រដូវប្រមូលផល) និងលក្ខខ័ណ្ឌផ្សេងៗ (សង្គម និង សេដ្ឋកិច្ច) រយៈពេល ១ឆ្នាំពេញ ។ ប្រតិទិនរដូវកាលនេះ បានបង្ហាញពីមុខសញ្ញាបង្កគ្រោះមហន្តរាយ ជំងឺ ការខ្វះស្បៀង បំណុល ភាពងាយរងគ្រោះ រួមទាំងសកម្មភាពអ្វីខ្លះដែលប្រជាជនបានធ្វើ ពេលដែលកំពុងមានបញ្ហាទាំងនេះ ហើយពួកគេប្រកបរបរចិញ្ចឹមជីវិតយ៉ាង

ដូចម្តេច ពេលណាដែលពួកគេរកចំណូលបានច្រើន ពេលណាពួកគេមានពេលវេលាសម្រាប់ ធ្វើការងារសហគមន៍ ហើយតើអ្វីជាដំណោះស្រាយជាយុទ្ធសាស្ត្ររបស់សហគមន៍។ ប្រតិទិននេះបង្ហាញឱ្យឃើញពីការបែងចែកការងាររបស់យ៉ែនឌ័រ ទាំងក្នុងពេលមានគ្រោះមហន្តរាយ និង ពេលគ្មានគ្រោះមហន្តរាយ ។

ប្រភេទបញ្ហាខុសៗគ្នានេះ គឺដាក់បញ្ចូលទៅក្នុងជួរឈរ ហើយខែដាក់នៅក្នុងជួរដេក ។ ដាក់អក្សរ x នៅតាមខែនីមួយៗ ដើម្បីបង្ហាញពីការកើតឡើងនៃបញ្ហាទៅតាមខែ ។ សូមមើលតារាងឧទាហរណ៍ដូចដែលមាននៅខាងក្រោម ។

**ការវិភាគក្រុមពាក់ព័ន្ធ :**

គូសដ្យាក្រាម ដែលបង្ហាញពីអង្គការ ក្រុម និងបុគ្គលសំខាន់ៗនៅក្នុងសហគមន៍ ទម្លាប់នៃការទំនាក់ទំនង និងកម្រិត នៃសារៈសំខាន់របស់ពួកគេ។ ដ្យាក្រាមនេះ គឺត្រូវបានធ្វើឡើងដើម្បីកំណត់ពីអង្គការ (ក្នុងមូលដ្ឋាន និងខាងក្រៅ) តួនាទី/សារៈសំខាន់របស់ពួកគេ និងទស្សនៈយល់ឃើញរបស់ប្រជាជនចំពោះពួកគេធ្វើការកំណត់នូវបុគ្គល ក្រុមអង្គការដែលដើរតួក្នុងការងារឆ្លើយតបគ្រោះមហន្តរាយ ហើយដែលអាចជួយគាំទ្រដល់សហគមន៍ផងដែរ ។ វាត្រូវបានធ្វើឡើងទៅតាមជំហានដូចតទៅនេះ

១- ក្រុមវីស៊ីអេ និងសហគមន៍ ធ្វើការកំណត់អង្គការ/ស្ថាប័នពាក់ព័ន្ធសំខាន់ៗ (៦-៨) ដែលធ្វើការងារសកម្មនៅក្នុងសហគមន៍ជាក់លាក់មួយ ។

២- អង្គការ/ស្ថាប័នទាំងនេះ ត្រូវបានយកមកធ្វើការចាត់អាទិភាព ពីទីតាំងរបស់អង្គការ/ស្ថាប័នដែលនៅជិតសហគមន៍ លេខ ៥ នៅក្នុងសហគមន៍ផ្ទាល់ និង លេខ ១ នៅក្រៅ (ឆ្ងាយ) ពីសហគមន៍ ។

៣- បន្ទាប់មកអង្គការ/ស្ថាប័នទាំងនេះ ត្រូវបានគេធ្វើការចាត់អាទិភាព ពីសារៈសំខាន់របស់ពួកគេចំពោះសហគមន៍ ដោយកម្រិតពីលេខ១ ដល់លេខ ៥ ហើយលេខ ៥ គឺខ្ពស់បំផុត និង លេខ ១ គឺទាបបំផុត ។

ឧបករណ៍នេះ បង្ហាញថា មានពេលខ្លះ អង្គការមួយចំនួនអាចមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសហគមន៍ ប៉ុន្តែអង្គការខ្លះទៀតនៅឆ្ងាយ ដែលមិនអាចឆ្លើយតបនឹងតម្រូវការសហគមន៍។ មានអង្គការខ្លះផ្សេងទៀត ដែលធ្វើការនៅក្នុងសហគមន៍ប៉ុន្តែបែរជាមិនត្រូវបានសហគមន៍ទទួលស្គាល់ថា

តារាងទី ៤ : ឧទាហរណ៍ប្រតិទិនរដូវកាល

| | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់ចំណូលទាប | | | | x | | | x | x | x | | | |
| ប្រាក់ចំណូលខ្ពស់ | x | x | x | | | | | | | | X | xx |
| អន្តោប្រវេសន៍និង ចំណាកស្រុក | x | x | x | x | x | xx | | | | | X | xx |
| គ្រោះថ្នាក់ចរាចរណ៍ | | | | x | | | | | x | | | X |
| ជំងឺរាគរូស | x | | | | | | | | | | X | x |
| ខ្យល់ព្យុះ | | | | | | x | x | x | x | x | X | |
| ភ្លើងឆេះព្រៃ | x | x | x | x | x | | | | | | | |
| គ្រោះរាំងស្ងួត | | | | | | x | x | x | | | | |
| គ្រោះទឹកជំនន់ | | | | | | | | x | x | x | | |
| អគ្គីភ័យ | | | | | | | | | | | | x |

សំខាន់ចំពោះពួកគេទៅវិញ ។ គំនិតជាទូទៅ គឺដើម្បីឆ្លុះបញ្ចាំងថាការងាររបស់អង្គការមួយចំនួន អាចឆ្លើយតបទៅនឹងតម្រូវការសហគមន៍បានល្អប្រសើរយ៉ាងណា? ប្រើប្រាស់ព័ត៌មានដែលបានមកពីប្រជាជន ប្រសើរជាងធ្វើការប៉ាន់ស្មានជំនួសពួកគេ ។

**គួរចងចាំថា :** នៅពេលធ្វើការចាត់ចំណាត់ថ្នាក់សមាជិកសហគមន៍និមួយៗ នឹងធ្វើការចាត់ចំណាត់ថ្នាក់ដោយខ្លួនឯងរៀងៗខ្លួននៅលើផ្ទាំងក្រដាស ការនិយាយផ្ទាល់មាត់ ឬការគូររូបភាពផ្សេងៗ ។ក្រោយមកធ្វើការបូកសរុបចម្លើយ ដើម្បីរកមធ្យមភាព។

**តារាងទី៥: ឧទាហរណ៍នៃការវិភាគក្រុមពាក់ព័ន្ធ និងសង្គម**

| ស្ថាប័ន | ទំនាក់ទំនង | មធ្យមភាព | សំខាន់ | មធ្យមភាគ |
|---|---|---|---|---|
| សមាគមស្ត្រី | (1-1-2-4-2) | 3 | (1-1-2-1-1) | 1.2 |
| កាកបាទក្រហម | (4-4-5-5-2) | 4 | (2-3-4-5-5) | 3.8 |
| សមាគមយុវជន | (5-3-2-2-2) | 2.6 | (5-2-1-4-3) | 2.5 |
| ធនាគារកសិករ | (2-4-4-5-4) | 3.8 | (1-5-4-5-5) | 4 |
| មូលនិធិជំងឺអេដស៍ | (1-4-5-4-1) | 3 | (1-5-5-4-2) | 3.4 |
| មណ្ឌលសុខភាព | (3-5-5-3-5) | 4.2 | (5-5-4-5-5) | 4.8 |

**ចេញពីការចុះអង្កេតជាក់ស្តែងឈានទៅកសាងផែនការតាមរយៈការគូសផែនទី--បទពិសោធន៍របស់កាកបាទក្រហមកម្ពុជា**



**សំនួរមួយចំនួន ខាងក្រោមនេះដែលអ្នកអាចប្រើ ដើម្បីដឹកនាំការពិភាក្សា :**

- តើប្រវត្តិរបស់អង្គការនោះយ៉ាងដូចម្តេច?
- តើអង្គការនោះត្រូវបានបង្កើតឡើងនៅពេលណា?
- ហេតុអ្វីបានជាគេបង្កើតអង្គការនោះ?
- តើអង្គការនោះមានសមាជិកប៉ុន្មាននាក់?

តើពួកគេធ្វើការដោយផ្ទាល់ ឬ ដោយប្រយោល?

- តើចំនួនតួលេខនៃសមាជិកនេះ កើនឡើង ឬថយចុះ?
- តើពួកគេចូលរួមពាក់ព័ន្ធយ៉ាងដូចម្តេច ក្នុងពេលប្រជុំ?
- តើការសម្រេចចិត្ត ត្រូវបានធ្វើឡើងយ៉ាងម្តេច?
- តើក្រុមនេះមានផែនការអភិវឌ្ឍន៍សហគមន៍ដែរឬទេ?
- តើក្រុមគណៈកម្មាធិការទាំងនោះមានដំនើរការដែរឬទេ?
- តើក្រុមនេះបានជួយផ្តល់អ្វីខ្លះដល់សហគមន៍នាពេលកន្លងមក ?

**៥. ការវិភាគព័ត៌មាន និងការរៀបចំព័ត៌មានជាប្រព័ន្ធ**

នៅពេលដែលអ្នក និងក្រុមការងារ ប្រជុំគ្នាម្តងទៀត ក្រុមការងារ អ្នកគួរតែបង្កើតនូវតារាងវិភាគមុខសញ្ញា ដែលអ្នកអនុវត្តវីស៊ីអេអាចទឹងចងចាំឡើងវិញបាន ។ សូមមើលតារាងទី៦ ខាងក្រោម :

ប្រសិនបើតារាងមុខសញ្ញាត្រូវបានធ្វើការវិភាគយ៉ាងត្រឹមត្រូវ នោះវានឹងបង្ហាញឱ្យឃើញពីគុណតម្លៃនៃការធ្វើវីស៊ីអេ ។ ដើម្បីបំពេញនៅក្នុងតារាងមុខសញ្ញាបាន លុះត្រាតែយើងធ្វើការពិនិត្យឡើងវិញនូវព័ត៌មានដែលប្រមូលបាន ដើម្បីឆ្លើយតបទៅនឹងសំនួរទាំងនេះ ។

**១- តើអ្វីជាហានិភ័យ**

ក- ធ្វើការកំណត់នូវមុខសញ្ញាគ្រោះមហន្តរាយដែលមានក្នុងសហគមន៍

ខ- ធ្វើការកំណត់ផលប៉ះពាល់ធ្ងន់ធ្ងរ ក្នុងករណីដែលមុខសញ្ញានេះ ពិតជាអាចកើតឡើងមានពិតប្រាកដមែន (ប្រសិនបើមានគ្រោះមហន្តរាយ) ។ ការកំណត់នូវ ផលប៉ះពាល់ រួមបញ្ចូលទាំងផ្នែករចនាសម្ព័ន្ធ មិនរចនាសម្ព័ន្ធ សង្គម សេដ្ឋកិច្ច ។ល។ តើអ្នកណាគេដែលងាយទទួលរងផលប៉ះពាល់ខ្លាំងជាងគេបំផុតនៅក្នុងសហគមន៍?

**២- តើអ្វីដែលធ្វើឱ្យប្រជាជនងាយរងគ្រោះ**

ធ្វើការកំណត់នូវធនធានដែលមានស្រាប់នៅក្នុងសហគមន៍ ដែលមានសមត្ថភាពអាចកាត់បន្ថយនូវហានិភ័យដែលបានរកឃើញ ហើយសមត្ថភាពទាំងនោះដែលត្រូវការ ដើម្បីទប់ទល់ទៅនឹងមុខសញ្ញាគ្រោះមហន្តរាយ ។

**តារាងទី៦: ឧទាហរណ៍នៃវិភាគម៉ាទ្រិកមុខសញ្ញាបង្កគ្រោះមហន្តរាយ**

| មុខសញ្ញា/បញ្ហា | ហានិភ័យដែលអាចកើតឡើង | ភាពងាយរងគ្រោះ | សមត្ថភាព | តម្រូវការបន្ទាន់ | សកម្មភាពកាត់បន្ថយ |
|---|---|---|---|---|---|
| ទឹកជំនន់ | ១. | ១.១ | ១. | ១. | ● |
| | ២. | ១.២ | ២. | ២. | ● |
| | ៣. | ១.៣ | ៣. | | ● |
| | ៤. | ១.៤ | | | ● |
| | | ២.១ | | | ● |

## ៣- តើអ្វីជាសមត្ថភាព

ក- ធ្វើការកំណត់នូវតម្រូវការភ្លាមៗ នៅពេលមានព្រឹត្តិការណ៍គ្រោះមហន្តរាយកើតឡើង ។

ខ- ធ្វើការកំណត់នូវសកម្មភាពកាត់បន្ថយដែលអាចធ្វើទៅបាន ប្រសិនបើគ្រោះមហន្តរាយកើតឡើង ។

**លទ្ធផលនៃថ្ងៃទី ១ នឹងមានផែនទីចំនួន ៤ (ផែនទីគោល ផែនទីមុខសញ្ញា/ហានិភ័យ ផែនទីធនធាន/សមត្ថភាព និង ផែនទីពំនូសកាត់ទទឹងភូមិ) + តារាងប្រវត្តិសហគមន៍ និងប្រវត្តិសហគមន៍ ប្រតិទិនរដូវកាល និងការវិភាគក្រុមពាក់ព័ន្ធ + តារាងមុខសញ្ញា/ហានិភ័យ/បញ្ហា**

## ថ្ងៃទី ២

១- ប្រជុំជាមួយសហគមន៍ ដើម្បីចែករំលែកលទ្ធផលដែលបានធ្វើការវិភាគពីថ្ងៃទី ១ និងបញ្ចូលទិន្នន័យបន្ថែមបើមាន ។

២- ផ្ទៀងផ្ទាត់តារាងជាមួយមនុស្សសំខាន់ៗ

៣- ជួបជាមួយក្រុមគោលដៅ ដែលជាកុមារ ស្ត្រី កសិករ/ អ្នកនេសាទ/កម្មករ ។ ក្រុមគោលដៅនឹងធ្វើការ ពិភាក្សាដោយផ្តោតលើមុខសញ្ញា និងភាពងាយរងគ្រោះ

៤-ប្រមូលព័ត៌មាន និងរៀបចំការងារ សម្រាប់ថ្ងៃបន្ទាប់ (ដំណើរការប្រែក្លាយភាពងាយរងគ្រោះជា សមត្ថភាព)

១- ប្រជុំជាមួយសហគមន៍ ដើម្បីចែករំលែកលទ្ធផលដែលបានធ្វើការវិភាគពីថ្ងៃទី១និងបញ្ចូលទិន្នន័យបន្ថែមបើមាន

ធ្វើការចែករំលែកនូវតារាងទាំងអស់ដែលបានបង្កើតឡើងជាមួយសហគមន៍ ដើម្បីទទួលបានព័ត៌មានសំខាន់ៗ នៅក្នុង



ការអង្កេតផ្ទាល់គឺសំខាន់ណាស់ និងចូលរួមគ្រប់ផ្នែកទាំងអស់នៃវគ្គបណ្តុះបណ្តាលការប៉ាន់ប្រមាណភាពងាយរងគ្រោះ និង សមត្ថភាព បទពិសោធន៍កាកបាទក្រហមឡាវ

សហគមន៍ ។ ធ្វើឱ្យមានការផ្លាស់ប្តូរព័ត៌មានសំខាន់ៗក្នុងតារាងជាមួយសហគមន៍ ។

បន្ទាប់មកទៀតបែងចែកសហគមន៍ទៅជាក្រុមតូចៗ (ដោយការចាប់ដាក់ឬតាមយ៉ៃនឆ៊ុរ ។ល។) ក្រុមនិមួយៗទទួលបាននូវតារាងមួយ ដែលខុសៗពីគ្នា ហើយពួកគេមានពេល ១៥នាទីដើម្បីគិតឡើងវិញ និងបញ្ចូលព័ត៌មានទៅក្នុងតារាងនោះ ។ បន្ទមកទៀត តារាងនេះនឹងបង្វិលទៅឱ្យក្រុមមួយផ្សេងទៀតដើម្បីពិនិត្យមើលទិន្នន័យដែលបញ្ចូលដោយក្រុមមុន ។ ដំណើរការនេះ គួរតែបន្តធ្វើរហូតដល់គ្រប់តារាងទាំងអស់ដែលត្រូវយកមពិនិត្យឡើងវិញនេះ ត្រូវបានបំពេញចប់សព្វគ្រប់ ។

## ២. ផ្ទៀងផ្ទាត់តារាងជាមួយមនុស្សសំខាន់ៗ

ក្រុមការងារវីស៊ីអេបានចងក្រងសេចក្តីព្រាងលើកទី ១ ទៅតាមតារាងនិមួយៗ ។ ឥឡូវនេះសាកសួរទៅមនុស្សសំខាន់ៗដើម្បីផ្តល់នូវព័ត៌មានសំខាន់ៗបន្ថែមទៀត ដើម្បីបង្កើននូវគុណភាពព័ត៌មាននៅក្នុងតារាង ។

ធានាថា មនុស្សសំខាន់ៗទាំងនោះយល់ថា សេចក្តីព្រាងចុងក្រោយនៃតារាងដែលមានបញ្ចូលព័ត៌មានថ្មីៗ ពីពួកគេនឹងត្រូវបង្ហាញជូនក្នុងពេលប្រជុំសហគមន៍ ដែលនឹងធ្វើឡើងនៅថ្ងៃទី ៣ បន្ទាប់ទៀត ។



កុមារគួរតែជាផ្នែកមួយនៃដំណើរការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព--បទពិសោធន៍ កាកបាទក្រហមឡាវ

## ៣. ការសំភាសន៍ក្រុមគោលដៅ

ក្រុមការងារវីស៊ីអេ គួរតែជ្រើសរើសសមាជិកក្រុមគោលដៅ។ វាជារឿងសំខាន់ ដែលត្រូវធ្វើសំភាសន៍ជាមួយក្រុមគោលដៅ កុមារ និងចាស់ព្រឹទ្ធាចារ្យ ឱ្យដាច់ដោយឡែកពីក្រុមដែលអាចផ្តល់ព័ត៌មានពីផ្នែកសង្គម និងសេដ្ឋកិច្ច ។ វាពិតជាមានសារៈសំខាន់បំផុត ដើម្បីបានដឹងនូវតម្រូវការស្របច្បាប់របស់មូលដ្ឋាន និងនីតិវិធីដ៏សមស្រប ដើម្បីធ្វើការជាមួយកុមារ និងអនីតិជន។ នៅគ្រប់ស្ថានភាពទាំងអស់ គ្រូបង្រៀននិង មន្ត្រីរាជការ ត្រូវតែមានវត្តមានចូលរួម។

ការសម្ភាសន៍ពាក់កណ្តាលផ្លូវការ មានជាច្រើនប្រភេទ ដូចជា ៖

- ការសម្ភាសន៍ជាក្រុម
- ការពិភាក្សាជាមួយក្រុមគោលដៅ
- ការសម្ភាសន៍ម្នាក់ៗ
- ការសម្ភាសន៍ជាមួយមនុស្សសំខាន់ៗ

សំនួរនាំមុខមួយចំនួនដូចខាងក្រោម អាចជួយអ្នកក្នុងពេលធ្វើការពិភាក្សាក្រុមគោលដៅ ៖

១- តើអ្នកទាំងអស់គ្នាជាអ្នករស់នៅក្នុងសហគមន៍មែនដែរឬទេ ? ហើយរស់នៅបានរយៈពេលប៉ុន្មានហើយ?

២- តើអ្វីទៅជាការព្រួយបារម្ភដ៏ធំបំផុតរបស់អ្នក ?

៣- តើអ្នកចង់សំណូមពរអ្វីខ្លះ ដែលអាចធ្វើទៅបាន ដើម្បីដោះស្រាយបញ្ហាដែលអ្នកកំពុងជួបប្រទះ?

៤- តើមានហេដ្ឋារចនាសម្ព័ន្ធអ្វីខ្លះ នៅក្នុងសហគមន៍អ្នក ?

៥- តើអ្វីទៅជាការព្រួយបារម្ភរបស់អ្នក ?

៦- តើមានជំងឺអ្វីខ្លះដែលប៉ះពាល់ដល់សហគមន៍របស់អ្នក?

៧- នៅពេលដែលមានអគ្គីភ័យ តើសហគមន៍នឹងធ្វើអ្វីខ្លះ ?

៨- តើអ្នកទុកដាក់សម្រាមយ៉ាងដូចម្តេច?

៩- តើមានគោលការណ៍ណែនាំស្តីពីការសាងសង់ ឬ ការសាងសង់អាគារបន្ថែមដែរឬទេ?

១០- តើអ្នកបានទឹកមកពីណាមកសម្រាប់ផឹក សម្រាប់បោកគក់ និង សម្រាប់ងូតទឹក?

១១- តើទម្លាប់ប្រចាំថ្ងៃរបស់អ្នកធ្វើអ្វីខ្លះ ?

១២- តើអ្នកណាខ្លះដែលកំពុងរស់នៅក្នុងផ្ទះ? សូមប្រាប់ពីអាយុ ភេទ និងត្រូវជាអ្វីនឹងអ្នក ។

១៣- តើអ្នកមានអារម្មណ៍យ៉ាងណាដែរ នៅពេលរស់នៅក្នុងតំបន់នេះ ?

១៤- ចូររៀបរាប់ពីរចនាសម្ព័ន្ធគ្រួសាររបស់អ្នក ហើយផ្តល់ឱ្យពួកគាត់យ៉ាងដូចម្តេច?

១៥- តើស្ថានភាពរស់នៅរបស់អ្នកយ៉ាងដូចម្តេច មុនពេល និង ក្រោយពេលមានខ្យល់ព្យុះ? តើអ្វីជាការផ្លាស់ប្តូរសំខាន់ក្នុងការរស់នៅប្រចាំថ្ងៃរបស់អ្នកបន្ទាប់ពីមានខ្យល់ព្យុះ?

១៦- តើអ្នកបានព្យាយាមធ្វើអ្វីខ្លះ ដើម្បីដោះស្រាយបញ្ហាដែលបានកើតឡើងហើយ?

## ៤. ប្រមូលព័ត៌មាន និងរៀបចំការងារសម្រាប់ថ្ងៃទី ៣ (ដំណើរការប្រែក្លាយ) ដែលដើម្បីរកឱ្យឃើញនូវ សមត្ថភាពថ្មីៗ

នៅពេលដែលបានពិភាក្សា និងវិភាគ យល់ព្រមលើព័ត៌មានទាំងអស់ដែលបានប្រមូលជាមួយសហគមន៍ហើយ វាចាំបាច់ដែលត្រូវបញ្ចូលទៅក្នុងទម្រង់ឯកសារជាអេឡិចត្រូនិច ។ ប្រសិនបើស្ថានភាពនៅក្នុងនោះ មិនអាចឱ្យយើងប្រើប្រាស់អគ្គិសនីបាន ដូចនេះព័ត៌មានដែលទទួលបានគួរតែរៀបចំកត់ត្រានៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ ។ ការធ្វើបែបនេះត្រូវចំណាយពេលច្រើនជាក់ជាមិនខាន តែមិនត្រូវមើលរំលងពីសារៈសំខាន់នៃកិច្ចការកត់ត្រាចងក្រងព័ត៌មានទាំងនេះទេ។

ការពាំនាំសុភមង្គល និងភាពញញឹម ដល់ប្រជាជន គឺជាផ្នែកមួយនៃអាណត្តិរបស់ចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហម

បទពិសោធន៍កាកបាទក្រហមឥណ្ឌូនេស៊ី




## ថ្ងៃទី ៣

១- ប្រជុំជាមួយសមាជិកសហគមន៍ ដើម្បីកំណត់ សកម្មភាព សម្រាប់ប្រែក្លាយពីភាពងាយរង គ្រោះទៅជា សមត្ថភាព និងដើម្បីបង្កើយការងារពាក់ពន្ធ័នឹង សកម្មភាពជាក់លាក់ សម្រាប់ការការពារ, កាត់បន្ថយ និងត្រៀមបង្ការ ។

២- ប្រមូលព័ត៌មាន និងចែករំលែកព័ត៌មានទៅសហគមន៍ មុនពេលចាកចេញ ។

## ១.ប្រជុំជាមួយសមាជិកសហគមន៍ ដើម្បីកំណត់នូវសកម្មភាពសម្រាប់ប្រែក្លាយពីភាពងាយរងគ្រោះទៅជាសមត្ថភាព

**គន្លឹះ :** *ត្រូវមានពេលវេលាឱ្យបានគ្រប់គ្រាន់ សម្រាប់សកម្មភាពនេះ ដើម្បីមនុស្សម្នាបញ្ចេញមតិយោបល់ដោយសេរី និងស្មោះត្រង់ ។*

លើកយកមកពិភាក្សាឡើងវិញនូវស្ថានភាពងាយរងគ្រោះពិតប្រាកដជាក់ស្តែងនានា ដែលបានរកឃើញ និងមានកត់ត្រាក្នុងតារាងនានា ។ វាជាការចាំបាច់ណាស់ដែលត្រូវចាត់សកម្មភាព

ទៅតាមប្រភេទជាក់លាក់ឆ្លើយតបនឹងភាពងាយរងគ្រោះនីមួយៗ។ ឧទាហរណ៍: ប្រសិនបើក្រុមបានកំណត់ថា សំណង់ដែលមិនសូវមានគុណភាព គឺជាភាពងាយរងគ្រោះ ក្នុងពេលដែលមានគ្រោះរញ្ជួយផែនដី ដូច្នេះសកម្មភាពផ្សេងៗដែលអាចឆ្លើយតបនឹងបញ្ហានេះ គឺមមាន : ការវិភាគទៅលើបច្ចេកទេសសាងសង់ដែលធ្លាប់អនុវត្តដោយសហគមន៍ កំនត់រកតំបន់ដែលងាយនឹងរងការខូចខាតខ្លាំងក្នុងសហគមន៍ វិភាគទៅលើរចនាសម្ព័ន្ធ កំណត់ពីកន្លែងគ្រោះថ្នាក់និងមានសុវត្ថិភាពនៅក្នុងផ្ទះ និងវិធានការដែលនឹងត្រូវអនុវត្តក្នុងពេលរញ្ជួយដី និងជាបន្ទាន់ បន្ទាប់ពីរញ្ជួយដី ។ល។

ដើម្បីប្រែក្លាយពីភាពងាយរងគ្រោះទៅជាសមត្ថភាព ត្រូវប្រើតារាងដូចខាងក្រោម :

**ប្រែក្លាយពីភាពងាយរងគ្រោះទៅជាសមត្ថភាព**

**កំនត់ចំណាំ:** ចូរចងចាំថា តារាងនេះត្រូវតែធ្វើឡើងដោយ ឬជាមួយសហគមន៍ ។ នៅពេលដែលមុខសញ្ញា និង ភាពងាយរងគ្រោះត្រូវបានរកឃើញ ដូចនេះដំណើរការដើម្បីប្រែក្លាយភាពងាយរងគ្រោះទៅជាសមត្ថភាព ត្រូវតែធ្វើជាមួយសមាជិកសហគមន៍។ តាមរយៈការងារនេះ សហគមន៍មានការកើនឡើងជាបន្តបន្ទាប់នូវកម្រិតភាពជាម្ចាស់របស់ពួកគាត់ ។ លើសពីនេះទៀតនោះ សហគមន៍

| បញ្ហា/មុខសញ្ញាគ្រោះមហន្តរាយ | ហានិភ័យ/ភាពងាយរងគ្រោះ | សកម្មភាពដើម្បីប្រែក្លាយពីភាពងាយរងគ្រោះទៅជាសមត្ថភាព |
|---|---|---|
| 1. ខ្វះជម្រក | - មនុស្សច្រើនរស់នៅក្នុងផ្ទះតែមួយ<br>- គ្មានភាពជាឯកជន<br>- ភាពងាយរងគ្រោះផ្នែកសង្គម | ផែនការធ្វើផ្ទះ |
| 2. ខ្វះសម្ភារៈសម្រាប់ផលិតកម្ម (កសិកម្ម) | - កង្វះអាហារូបត្ថម្ភចំពោះកុមារ<br>- ការបោះបង់ការសិក្សា<br>- ខ្វះស្បៀងច្រើនខែ<br>- ចំណាកស្រុក | -ផ្តល់ឧបករណ៍ផលិត<br>-វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ |
| 3. សំណឹកដី (ទន្លេ និងសមុទ្រ) | - ដំណាំមិនបានផល (ដោយសារតែទឹក ប្រៃ)<br>- ផលិតកម្មវារីវប្បកម្មមិនបានផល | - ពង្រឹងរបាំងសមុទ្រ/ទំនប់ទន្លេ<br>- ដាំដើមឈើតាមដងទន្លេ/សមុទ្រ ការពារ និងបម្រុងទុក |
| 4. ខ្វះការអប់រំ/ការបណ្តុះបណ្តាលវិជ្ជាជីវៈ | - ការយល់ដឹងពីហានិភ័យនៅមានកម្រិត<br>- ការធ្វើចំណាកស្រុក(បុរស)ហើយនៅពេលមានគ្រោះមហន្តរាយកើតឡើងគ្មាននរណាជួយ | - អប់រំផ្សព្វផ្សាយពីហានិភ័យ<br>- វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ |
| 5. រកប្រាក់ចំនូលបានទាប | គុណភាពជីវិតរស់នៅទាប | ធ្វើផែនការរកប្រាក់ចំណូល |
| 6. ផ្លូវធ្វើដំណើរតូចចង្អៀត | - គ្រោះថ្នាក់ចរាចរណ៍<br>- ពិបាកក្នុងការដឹកជញ្ជូន | - អប់រំផ្សព្វផ្សាយ<br>- ធ្វើផ្លូវឱ្យធំជាងមុន |
| 7. មិនមានសួនកុមារ និងកន្លែងលំហែកាយ | សុខភាពមិនល្អ | កសាងកន្លែងកំសាន្ត |

**តារាងទី៧: ឧទាហរណ៍នៃការប្រែក្លាយពីភាពងាយរងគ្រោះទៅជាសមត្ថភាព**

នឹងមានសិទ្ធិធ្វើសកម្មភាពប្រែក្លាយទាំងនេះដោយសហគមន៍ខ្លួនគាត់ផ្ទាល់ដែរ។

**របៀបនៃការប្រែក្លាយទៅជាសកម្មភាពជាក់លាក់នានា**

ឥឡូវនេះយើងនឹងសិក្សាពីយន្តការនានា ដើម្បីធ្វើឱ្យប្រាកដថា ពួកគាត់អាចអនុវត្តសកម្មភាពដែលបានរៀបចំឡើង។ ដើម្បីធ្វើទៅបាន យើងត្រូវចងចាំនូវចំនុចដូចតទៅ៖

ក. តើបញ្ហានេះអាចធ្វើជាបន្ទាន់ដែរឬទេ ?

ខ. តើវាត្រូវការធនធានដែរឬទេ ?

គ. តើយើងអាចស្វែងរកធនធានចាំបាច់ដោយខ្លួនយើងបានដែរឬទេ ? ប្រសិនបើបាន តើស្វែងរកយ៉ាងដូចម្តេច ?

ឃ. តើវាត្រូវការជំនួយបច្ចេកទេសដែរឬទេ ? បើត្រូវការ តើយើងរកពីកន្លែងណា ?

ដំណោះស្រាយត្រូវតែជាផ្នែកមួយនៃជំនាញ និង/ឬធនធានដែលមានស្រាប់នៅក្នុងសហគមន៍។ ប្រសិនបើដំណោះស្រាយនោះ

| សកម្មភាព | រយៈពេលខ្លី/មធ្យម/វែង | ថវិកា ? | រកធនធានពីណា ? | ការគាំទ្រផ្នែកបច្ចេកទេស ? |
|---|---|---|---|---|
| 1. ផែនការធ្វើផ្ទះ | រយៈពេលវែង | ត្រូវការ | - ដី : អាជ្ញាធរមូលដ្ឋាន<br>- កម្លាំងពលកម្ម : សហគមន៍<br>- ថវិកាដើម្បីទិញសម្ភារៈសាងសង់ : ម្ចាស់អំណោយខាងក្រៅ | ត្រូវការ (ជាងសាងសង់) |
| 2. ផ្តល់ឧបករណ៍ផលិតកម្ម | មធ្យម | ត្រូវការ | អាជ្ញាធរមូលដ្ឋាន និងសហគមន៍ | ទេ |
| 3. ដាំដើមឈើ | វែង | ត្រូវការ | - ដី : អាជ្ញាធរមូលដ្ឋាន<br>- កម្លាំងពលកម្ម : សហគមន៍<br>- ពូជ : សហគមន៍ និងម្ចាស់ អំណោយ<br>- ការថែរក្សា : សហគមន៍ | ត្រូវការ (ជំនាញកសិកម្ម) |
| 4. អប់រំផ្សព្វផ្សាយ | មធ្យម | ត្រូវការ | - ធនធានមនុស្ស : សហគមន៍<br>- ទីកន្លែង : សហគមន៍<br>- ថវិកា : អាជ្ញាធរមូលដ្ឋាន/ម្ចាស់អំណោយ<br>- ឧបករណ៍:សហគមន៍/CBOs | ត្រូវការ (បច្ចេកទេសពីសាលា ឬស្ថាប័នផ្សេងៗ) |
| 5. ផែនការរកចំណូល | មធ្យម | ត្រូវការ | អាជ្ញាធរមូលដ្ឋាន/ធនាគារ/ម្ចាស់អំណោយ | ត្រូវការ (បច្ចេកទេស) |
| 6. ធ្វើផ្លូវឱ្យធំជាងមុន | វែង | ត្រូវការ | រដ្ឋាភិបាល និងសហគមន៍ | ត្រូវការ |
| 7. កសាងកន្លែងកំសាន្ត | មធ្យម | ត្រូវការ | សហគមន៍ អាជ្ញាធរមូលដ្ឋាននិងម្ចាស់អំណោយ | ត្រូវការ |

**តារាងទី៨: ឧទាហរណ៍មួយនៃរូបភាពពីការស្វែងរកដំណោះស្រាយផ្សេងៗ**

ត្រូវការថវិកា ដូចនេះការរកមូលនិធិក៏ជាផ្នែកមួយនៃដំណោះស្រាយដែរ (ជាមួយគំនិតច្នៃប្រឌិត ដូចជាបង្កើតឆ្នោតវត្ថុ រាត្រីសមោសរ ការរ៉ៃអង្គាសផ្សេងៗជាដើម) ។ ប្រសិនបើវាពិតជាត្រូវការជំនាញ ដូចនេះគួរតែរកនៅក្នុងសហគមន៍ផ្ទាល់ រួមបញ្ចូលទាំងមិត្តភក្តិ សាច់ញាតិជាដើម ។ ធនធានចុងក្រោយបំផុតគួរតែត្រលប់ទៅរកអ្នកដែលនៅខាងក្រៅសហគមន៍វិញម្តង ។ (តារាងទី៨)

សកម្មភាពទាំងឡាយខាងលើ ដើម្បីប្រែក្លាយភាពងាយរងគ្រោះទៅជាសមត្ថភាពទាំងនេះទាមទាឱ្យមានការពិនិត្យពិច័យសម្រាប់ជំហានបន្ទាប់ ដែលយើងសង្ឃឹមថាអាចធ្វើសកម្មភាពជាក់លាក់ពិតប្រាកដនៅក្នុងសហគមន៍ ។ ការវិភាគលើក្រុមពាក់ព័ន្ធសហគមន៍ ដែលបាន (ការវិភាគបណ្តាញស្ថាប័ន និងសង្គម) វាជាការចាប់ផ្តើមដ៏សំខាន់ ។

## ២. ការរៀបចំចងក្រងព័ត៌មាន និងការចែករំលែកមុនពេលចាកចេញពីសហគមន៍

នេះជាពេលចុងក្រោយនៃការប្រមូលពត៌មាន ។ ពេលចងក្រងព័ត៌មានចប់សព្វគ្រប់ ហើយក្រុមការងារគួរបង្ហាញនូវគំហើញសំខាន់ៗ និងផែនការសកម្មភាពដល់សហគមន៍ (ប្រធាន និងសមាជិក) សម្រាប់ពិនិត្យឡើងវិញ និងផ្ទៀងផ្ទាត់ម្តងទៀតមុនពេលចាកចេញពីសហគមន៍ និងធ្វើការបញ្ចប់ ។ នៅពេលរបាយការណ៍ និង ផែនការសកម្មភាពបញ្ចប់ យើងត្រូវការចែករំលែកជាមួយសហគមន៍ម្តងទៀត និងវាជារឿងចាំបាច់សម្រាប់ពួកគាត់ ដើម្បីធ្វើការគៀងគររកធនធានជាមួយក្រុមពាក់ព័ន្ធ ឬម្ចាស់ជំនួយបច្ចេកទេសប្រសិនបើចាំបាច់ ។ ក្រុមការងារត្រូវចែករំលែកនូវលទ្ធផលដល់សាខា និងសមាគមជាតិ ព្រមទាំងម្ចាស់ជំនួយពាក់ព័ន្ធដើម្បីធ្វើអន្តរាគមន៍ ។ គួរពិចារណាបញ្ចូលលទ្ធផលការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព ទៅក្នុងផែនការអភិវឌ្ឍន៍សហគមន៍ដែលជាអន្តរាគមន៍រយៈពេលវែង ។

ការធ្វើបច្ចុប្បន្នភាព ការពិនិត្យតាមដាន និង ការវាយតំលៃឱ្យបានទៀងទាត់ ទៅលើភាពរីកចំរើននៃការអនុវត្តន៍ផែនការសកម្មភាពដែលបានចងក្រង និងអនុវត្តជាកិច្ចការចាំបាច់ ដើម្បីពិនិត្យរកមើលថា តើសហគមន៍ ត្រូវការការគាំទ្រជាបច្ចេកទេស និងសម្ភារៈអ្វីខ្លះរឺទេ ។ ការផ្លាស់ប្តូរទាំងឡាយដែលកើតមានឡើងនៅក្នុងសហគមន៍គួរតែត្រូវ បានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់សមាគមជាតិ ក្នុងវិស័យការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ។

ជាចុងក្រោយ និងមានសារៈសំខាន់បំផុត គឺបណ្តុះបណ្តាលតាមរយៈការធ្វើការងារដោយផ្ទាល់ សម្រាប់សមាជិកសហគមន៍ក្នុងកំឡុងពេលដំណើរការទាំងមូល ដើម្បីឱ្យពួកគាត់អាចគ្រប់គ្រងដោយខ្លួនពួកគាត់ផ្ទាល់ ។

---

## ឯកសារយោង


- តើអ្វីទៅជាការប៉ាន់ប្រមាណភាពងាយរង គ្រោះ និងសមត្ថភាព ? (សហព័ន្ធអន្តរជាតិ ឆ្នាំ ២០០៧)
- តើយើងធ្វើការប៉ាន់ប្រមាណភាពងាយគ្រោះ និងសមត្ថភាព យ៉ាងដូចម្តេច ?(សហព័ន្ធអន្តរជាតិ ឆ្នាំ ២០០៧)
- ប្រអប់ឯកសារការប៉ាន់ប្រមាណភាពងាយរង គ្រោះ និងសមត្ថភាព? (សហព័ន្ធអន្តរជាតិ ឆ្នាំ ២០០៧)
- ឯកសារណែនាំវគ្គបណ្តុះបណ្តាលការប៉ាន់ប្រមាណភាពរងគ្រោះ និងសមត្ថភាព (សហព័ន្ធអន្តរជាតិ ឆ្នាំ ២០០៧)



**អ្នកស្ម័គ្រចិត្តកាកបាទក្រហមជួយសហគមន៍កសាង “ សត្វនាគដុំថ្ម” ដើម្បីការពារជ្រាំងទន្លេពីសំណឹក បទពិសោធន៍កាកបាទក្រហមទីម័រខាងកើត**

## ឧបសម្ព័ន្ធទី១:

### គំនូសតាងពន្យល់ពីដំណើរការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព



## ឧបសម្ព័ន្ធទី ២:

### តារាងកាលវិភាគនៃការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាពជាមួយសហគមន៍

ឧទាហរណ៍តារាងកាលវិភាគនៃការប៉ាន់ប្រមាណភាពរងគ្រោះ និងសមត្ថភាព

| រយៈពេល | សកម្មភាពសម្រាប់ថ្ងៃទី ១ |
|---|---|
| 30នាទី | ការណែនាំទៅដល់សហគមន៍<br>i. ពន្យល់គោលបំណងថ្ងៃនេះ<br>ii. បង្ហាញសមាជិកក្រុម<br>iii. តើនឹងមានអ្វីកើតឡើងនៅក្នុងថ្ងៃនេះ<br>iv. បែងចែកក្រុម អាស្រ័យទៅលើការរៀបចំរបស់សហគមន៍ |
| 2ម៉ោង | • ជួបជាមួយក្រុមគោលដៅចំនួនពីរ (ឧ. ក្រុមស្ត្រី និង ក្រុមកសិករ) ធ្វើការសម្ភាសន៍ជាមួយមនុស្សសំខាន់ៗក្នុងសហគមន៍ (គ្រូបង្រៀន ចាស់ព្រឹទ្ធាចារ្យ ពេទ្យ...)<br>• ធ្វើពំនូសកាត់ទទឹងភូមិ និងផ្តោតទៅលើការសង្កេតផ្ទាល់ |
| 1ម៉ោង និង30 នាទី | - លំហាត់គូសផែនទីជាមួយក្រុមមនុស្ស ១០នាក់<br>• ប្រវត្តិសហគមន៍<br>• តារាងប្រតិទិនរដូវកាល |
| 1 ម៉ោង | សម្រាកអាហារថ្ងៃត្រង់ : ការពិភាក្សាទៅលើភាពជឿនលឿន ការសង្កេតផ្ទាល់ (ត្រូវ ចង់ចាំថា អ្នកអាចផ្តល់អាហារថ្ងៃត្រង់ និង/ឬអាហារសម្រន់សម្រាប់អ្នកចូលរួម និងជា ពិសេសអ្នកស្ម័គ្រចិត្ត) |
| 2 ម៉ោង | ការប៉ាន់ប្រមាណតាមគ្រួសារ/ភាពងាយរងគ្រោះ ដែលនៅជុំវិញ<br>ប៉ាន់ប្រមាណសមត្ថភាពរបស់ក្រុមពាក់ព័ន្ធ |
| 1 ម៉ោង | វាយតម្លៃលទ្ធផលថ្ងៃទី ១ និងធ្វើការរៀបចំសម្រាប់ថ្ងៃបន្ទាប់ |

## ឧបសម្ព័ន្ធ ៣:

## ធាតុផ្សំសំខាន់ៗសម្រាប់ធ្វើការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព

វាជាការសំខាន់ ដើម្បីទទួលស្គាល់ថា ការអនុវត្តប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព ត្រូវការពេលវេលា និងធនធាន ។ សូមពិនិត្យមើលទៅ តាមចំនុចដូចខាងក្រោម :

| | |
|---|---|
| **គោលបំណង** | **កំណត់ និងសរសេរឱ្យបានច្បាស់នូវគោលបំណងនៃការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព** |
| **ទីកន្លែង** | តំបន់ដែលជ្រើសរើសសម្រាប់ធ្វើការប៉ាន់ប្រមាណភាពងាយរងគ្រោះ និង សមត្ថភាព គួរតែជាតំបន់មាន គ្រោះមហន្តរាយ ឬ សហគមន៍ ឬ ភូមិ ដែល ប្រឈមមុខនឹងហានិភ័យ |
| **ក្រុមប៉ាន់ប្រមាណ** | រួមបញ្ចូលទាំងអ្នកសម្របសម្រួល និងអ្នកតំណាងសហគមន៍ អ្នកសម្របសម្រួលរបស់ចលនាកាកបាទក្រហម/អឌ្ឍចន្ទក្រហម ដើរតួនាទីជាអ្នកគាំទ្រនៅក្នុង ដំណើរការប៉ាន់ប្រមាណ ។ អ្នកតំណាងសហគមន៍ នឹងដើរតួយ៉ាងសំខាន់ក្នុងការ សម្របសម្រួលការពិភាក្សា ។ |
| **អ្នកចូលរួម** | មតិភាគច្រើនគឺបានមកពីអ្នកភូមិ តំណាងក្រុមផ្សេងៗ ( អាយុ សាសនាមុខរបរ យ៉េនឌ័រ អ្នកពិការ ។ល ។) តំណាងអង្គការសហគមន៍មូលដ្ឋាន និងអាជ្ញាធរ ដែនដី ។ |
| **ឧបករណ៍** | ឧបករណ៍ប៉ាន់ប្រមាណហានិភ័យតាមបែបចូលរួម ( PRA ) ឧ. ការអង្កេតផ្ទាល់ ផែនទី មុខសញ្ញាបង្គ្រោះមហន្តរាយ ពំនូសកាត់ទទឹងភូមិ ប្រតិទិនរដូវកាល ប្រវត្តិ សហគមន៍ ការវិភាគក្រុមពាក់ព័ន្ធ ការវិភាគបញ្ហាតាមរូបភាពដើមឈើ ដែលឧបករណ៍ភាគច្រើន ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដើម្បីប្រមូលព័ត៌មាន និងវិភាគព័ត៌មាន ។ ជ្រើស រើសឧបករណ៍ ដែលសាកសមបំផុតសម្រាប់យកមកអនុវត្ត ។ |
| **ដំណើរការ** | **ផែនការ :** រៀបចំផែនការសកម្មភាពក្រុមប៉ាន់ប្រមាណភស្តុភា និងសម្ភារៈប្រើប្រាស់ផ្សេងៗ→ **ការស្វែងរកការគាំទ្រមតិ** ទៅអាជ្ញាធរមូលដ្ឋាន ដើម្បីឱ្យមានការចូលរួមពីប្រជាជនឱ្យបានកាន់តែច្រើននៅថ្នាក់ភូមិ និងតាមដានលទ្ធផលប៉ាន់ប្រមាណភាពងាយរងគ្រោះនិងសមត្ថភាព→ **ប្រមូលព័ត៌មាន** → តាមទិន្នន័យ ដែលមានស្រាប់ → តាមរយៈអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដោយប្រើប្រាស់ឧបករណ៍ PRA → **វិភាគ**មុខសញ្ញាបង្គ្រោះមហន្តរាយ ភាពងាយរងគ្រោះ សមត្ថភាពនិងហានិភ័យ→ ផ្ទៀងផ្ទាត់/បញ្ជាក់ព័ត៌មានជាមួយសហគមន៍→ **ផែនការសម្រាប់ការប្រែក្លាយ**ពីភាពងាយរងគ្រោះទៅជាសមត្ថភាព → **របាយការណ៍** → ពិនិត្យតាមដាន( ការធ្វើសមាហរណកម្មទៅក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋាន) |

| គោលបំណង | កំណត់ និងសរសេរឱ្យបានច្បាស់នូវគោលបំណងនៃការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព |
|---|---|
| លទ្ធផល | • ព័ត៌មានដែលបានមកពីការប៉ាន់ប្រមាណនេះ គឺអាចប្រើ ជាឯកសារយោងនៅពេល ធ្វើការប៉ាន់ប្រមាណតម្រូវការនៅពេលគ្រោះអាសន្ន និង ការងារត្រៀមបង្ការគ្រោះមហន្តរាយ ។<br>• សហគមន៍យល់ពីស្ថានភាពនៃមុខសញ្ញាបង្កគ្រោះមហន្តរាយ និងហានិភ័យ<br>• សហគមន៍អាចមើលឃើញពីសមត្ថភាពដែលគេមាន ដើម្បីទប់ទល់ជាមួយមុខសញ្ញា បង្កគ្រោះមហន្តរាយ និង ហានិភ័យ ។<br>• សហគមន៍ និងអាជ្ញាធរមូលដ្ឋានព្រមព្រៀងនូវសកម្មភាពចាំបាច់ ដើម្បីការពារ ឬ កាត់បន្ថយផលប៉ះពាល់ដោយគ្រោះមហន្តរាយ ។<br>• សហគមន៍បានអនុវត្ត គម្រោងលើការងារកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ដូចជា ការកាត់បន្ថយ ការការពារ ការត្រៀមបង្ការ និងបានធ្វើការ វាយតម្លៃ ពីការអនុវត្តន៍គំរោងទាំងនេះ ។ |

## ឧបសម្ព័ន្ធ ៤ :
## តារាងព័ត៌មានប្រចាំថ្ងៃ នៅក្នុងសហគមន៍

| ប្រអប់ព័ត៌មានប្រចាំថ្ងៃ | |
|---|---|
| **សកម្មភាព** | **លទ្ធផលរំពឹងទុក** |
| **ថ្ងៃទី ១** | |
| 1. | - |
| 2. | - |
| 3. | - |
| 4. | - |
| **ថ្ងៃទី ២** | |
| 1. | - |
| 2. | - |
| 3. | - |
| 4. | - |
| **ថ្ងៃទី ៣** | |
| 1. | - |
| 2. | - |
| 3. | - |
| 4. | - |

# គោលការណ៍គ្រឹះនៃចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហមអន្តរជាតិ

## ភាពមនុស្សធម៌

ចលនាអន្តរជាតិកាកបាទក្រហម អឌ្ឍចន្ទក្រហម កើតឡើងដោយបំណងប្រាថ្នាសំដៅជួយជនរងរបួសនៅក្នុងសមរភូមិ ដោយមិនបែងចែក ឬ រើសអើង។ ខិតខំខ្នះខ្នែងទៅតាមសមត្ថភាពជាតិ និងអន្តរជាតិរបស់ខ្លួន ដើម្បីបង្ការ និងកាត់បន្ថយទុក លំបាកវេទនារបស់មនុស្សលោកនៅគ្រប់ទីកន្លែងដែលជួបប្រទះ ។ គោលបំណងនៃចលនា គឺការពារជីវិត និងសុខភាព ហើយធានា ការគោរពមនុស្សលោក ។ ចលនានឹងលើកកម្ពស់ការយោគយល់គ្នាទៅវិញ-ទៅមក មិត្តភាពសហប្រតិបត្តិការ និងសន្តិភាពស្ថិតស្ថេរ ក្នុងចំណោមជនគ្រប់រូប ។

## ភាពមិនលំអៀង

ជាភាពមិនបែងចែក ឬរើសអើងសញ្ជាតិ ពូជសាសន៍ ជំនឿ សាសនា វណ្ណៈ ឬទស្សនទយោបាយឡើយ ។ ភាពមិនលំអៀងខិតខំប្រឹង ប្រែងសម្រាលការឈឺចាប់ខ្លោចផ្សាររបស់ជនគ្រប់រូប ដោយចំពោះតែអ្នកដែលត្រូវការឱ្យជួយ និងជូនអាទិភាពដល់ករណី ដែលជាគ្រោះអាសន្នជាងគេ ។

## អព្យាក្រិតភាព

ដើម្បីបន្តរក្សាក្តីសោមនស្សរីករាយ និងជំនឿទុកចិត្តពីគ្រប់មជ្ឈដ្ឋាន ចលនាមិនគប្បីចូលរួមក្នុងអរិភាព ឬ ទោះជាក្នុង កាលៈទេសៈណាក៏ដោយ មិនចូលរួមក្នុងការវែកញែករកខុសត្រូវក្នុងបញ្ហានយោបាយ ពូជសាសន៍ សាសនា មនោគមន៍វិជ្ជាឡើយ ។

## ឯករាជ្យភាព

ចលនាត្រូវតែឯករាជ្យ ។ សមាគមជាតិទោះជាជំនួយការឱ្យរដ្ឋាភិបាលខាងសេវាកម្មមនុស្សធម៌ និងស្ថិតនៅក្រោមច្បាប់ របស់ប្រទេសជាតិក៏ដោយ ក៏ជានិច្ចកាលត្រូវតែរក្សាស្វ័យភាពរបស់ខ្លួន ដើម្បីអាចធ្វើសកម្មភាពបានស្របតាមគោលការណ៍គ្រឹះនៃចលនា ។

## សេវាកម្មស្ម័គ្រចិត្ត

គឺជាអង្គការសង្គ្រោះដោយស្ម័គ្រចិត្តមួយ ដែលមិនមែនធ្វើសកម្មភាពដោយសារតែចង់បានចំណេញនោះឡើយ ។

## ឯកភាព

នៅក្នុងប្រទេសមួយអាចមានសមាគមជាតិតែមួយគត់ ។ សមាគមជាតិនោះត្រូវតែបើកចំហរជូនជនគ្រប់រូប ហើយ ត្រូវបំពេញភារៈកិច្ចមនុស្សធម៌នៅទូទាំងប្រទេស ។

## សកលភាព

ចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហមអន្តរជាតិ ក្នុងនោះគ្រប់សមាគមជាតិទាំងអស់មានឋានៈស្មើគ្នា មានការទទួលខុសត្រូវ និងករណីយកិច្ចដូចៗគ្នា ក្នុងការជួយគ្នាទៅវិញទៅមក គឺជាលក្ខណៈសកល ។

ទាំងអស់គ្នាដើម្បីមនុស្សធម៌

សហព័ន្ធអន្តរជាតិនៃសមាគមកាកបាទក្រហម និងអឌ្ឍចន្ទក្រហមលើកតំកើងសកម្មភាពមនុស្សធម៌ នៃសមាគមជាតិក្នុងចំណោមប្រជាជនងាយរងគ្រោះទាំងអស់ ។

តាមរយៈការសំរបសំរួលផ្តល់ជំនួយសង្គ្រោះជាលក្ខណៈអន្តរជាតិលើការងារគ្រោះមហន្តរាយ និងលើកទឹកចិត្តឱ្យមានការគាំទ្រដល់ការ អភិវឌ្ឍន៍ដោយអំពាវនាវឱ្យមានការការពារ និងកាត់បន្ថយនូវសេចក្តីឈឺចាប់របស់មនុស្សជាតិ ។

សហព័ន្ធអន្តរជាតិ សមាគមជាតិ និងកាកបាទក្រហម និងអឌ្ឍចន្ទក្រហមអន្តរជាតិ រួមទាំងសមាសភាពនៃចលនាកាកបាទក្រហម និងអឌ្ឍចន្ទក្រហមអន្តរជាតិ ។



កសាងសុវត្ថិភាព និងធ្វើឱ្យសហគមន៍មានភាពរឹងមាំអាចទប់ទល់
នឹងគ្រោះមហន្តរាយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍